មេរៀនទី ១០

# អនាគត៖ ការបើកបង្ហាញ ចុងក្រោយ និង ការសម្រាក

ព្រះគម្ពីរមានរឿងជាច្រើន និយាយអំពីការបំពេញតាមផែនការរបស់ព្រះជាម្ចាស់ សម្រាប់ប្រជារាស្ត្ររបស់ទ្រង់។ នៅក្នុងព្រះបន្ទូលដំបូងបង្អស់របស់ទ្រង់ បន្ទាប់ពីបុណ្យថ្ងៃទីហាសិប លោកពេត្រុសបានប្រកាសថានៅក្នុងថ្ងៃអនាគត ព្រះជាម្ចាស់នឹងស្រោចស្រង់អ្វីៗគ្រប់យ៉ាង (គម្ពីរកិច្ចការ ៣:២១)។ បន្ទាប់មក ជាមួយពាក្យដ៏គួរឲ្យជំរុញចិត្ត លោកសាវ័កប៉ុលបានបង្ហាញពីលក្ខណៈនៃអ្វីដែលត្រៀមទុកសម្រាប់គ្រិស្តបរិស័ទ នៅថ្ងៃមុខ (គម្ពីររ៉ូម ៨:១៨-២៥)។ លោកបានមានប្រសាសន៍ថា របស់សព្វសារពើ កំពុងតែទន្ទឹងរង់ចាំការបើកបង្ហាញ ផែនការនៃការប្រោសលោះរបស់ព្រះជាម្ចាស់។

តាំងពីពេលដែលមនុស្សជាតិបានធ្លាក់ចុះ ធម្មជាតិបានធ្លាក់ទៅក្រោមឥទ្ធិពលដ៏អាក្រក់ នៃបណ្តាសារ។ មនុស្សជាតិក៏បានស្រែកថ្ងូរ នៅក្រោមបន្ទុកនៃការបង្ខិតបង្ខំឲ្យរស់នៅដោយភាពខ្វះខាត ដែលបានមកពីផែនដីដែលត្រូវបណ្តាសារអំពើបាប និង ដ៏ចចេសរឹងរូសមួយនេះ។ ខ្លួនប្រាណរបស់យើងបានរងទុក្ខពីជំងឺ និង ការពុកផុយរលួយ។ ជាមួយនឹងត្រចៀកដែលផ្ទៀងស្តាប់ព្រះសូរសៀងព្រះអាទិកររបស់យើង យើងរាល់គ្នា (រួមជាមួយនឹងស្នាព្រះហស្តរបស់ទ្រងផ្សេងទៀត) ទន្ទឹងរង់ចាំព្រះបន្ទូលដែលថ្លែងព្រះពរថា៖ "អ្វីៗទាំងអស់នឹងលែងត្រូវបណ្តាសាទៀតហើយ" (គម្ពីរវិវរណៈ ២២:៣)។ ពេលវេលានឹងឈានចូលមកដល់ នៅពេលដែលព្រះជាម្ចាស់នឹងដោះស្រាយជាមួយនឹងប្រភពដើមនៃបញ្ហាទាំងអស់នេះ។ មនុស្ស រួមទាំងសាតាំងផង នឹងត្រូវកាត់ទោស ហើយព្រះយេស៊ូនឹងយាងមកយកមនុស្សសុចរិតទៅជាមួយទ្រង់នៅឯស្ថានបរមសុខ។ នោះគឺជាសេចក្តីសង្ឃឹមដ៏មានពររបស់អ្នកជឿ!

នៅក្នុងមេរៀននេះ យើងនឹងពិភាក្សាគ្នាអំពីការបំពេញតាមបទទំនាយនៅក្នុងព្រះគម្ពីរ និង ការសម្រេចផែនការរបស់ព្រះជាម្ចាស់នៅថ្ងៃអនាគត។ នៅពេលដែលយើងពិចារណាអំពីបញ្ហាសំខាន់ៗទាំងអស់នេះ សូមឲ្យសេចក្តីសង្ឃឹមដែលព្រះបានប្រទានមក ជួយឲ្យអ្នកសិក្សាអំពីខ្លួនឯងឲ្យកាន់តែច្បាស់ និង បន្សុទ្ធខ្លួនឯងឲ្យល្អលះអស់នូវអ្វីៗដែលអាចរារាំងអ្នក ពីការត្រៀមខ្លួនសម្រាប់ការយាងត្រឡប់មករបស់ព្រះអម្ចាស់នៃយើង។

## *គម្រោងមេរៀន*

ក. សេចក្ដីសង្ឃឹមដ៏មានពរ

ខ. ទុក្ខវេទនា

គ. ការបើកសម្ដែងរបស់ព្រះយេស៊ូគ្រិស្ដ

ឃ. រយៈពេលមួយពាន់ឆ្នាំ

ង. ការវិនិច្ឆ័យសាតាំង និង មនុស្សអាក្រក់ដែលបានស្លាប់

ច. ការបង្កើតថ្មី

## *វត្ថុបំណងមេរៀន*

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹងៈ

១. កំណត់និយមន័យពីសេចក្ដីសង្ឃឹមដ៏មានពរ។

២. ពិភាក្សាថាតើ ព្រឹត្តិការណ៍នៃបទទំនាយណាខ្លះ នៅក្នុងគម្ពីរដានីយ៉ែលជំពូក ៩ និង អេម៉ុសជំពូក៩ បានកើតមានឡើងរួចទៅហើយ។

៣. បកស្រាយព្រឹត្តិការណ៍នៅក្នុងសម័យរបស់អ្នកប្រឆាំងនឹងព្រះគ្រិស្ដ និង សមរភូមិនៅឯអើម៉ាគេដូន។

៤. បកស្រាយថាតើមានលក្ខខ័ណ្ឌអ្វីខ្លះ ដែលនឹងនាំឲ្យមានការបើកសម្ដែងរបស់ព្រះគ្រិស្ដ និង រៀបរាប់អំពីលទ្ធផលចុងក្រោយរបស់អ្នកដឹកនាំនៃគូបដិបក្សទាំងពីរ។

៥. ពិភាក្សាអំពីគោលបំណង និង រៀបរាប់អំពីលក្ខណសម្បត្តិនៃរាជ្យមួយពាន់ឆ្នាំ។

៦. បកស្រាយមូលហេតុដែលសាតាំង នឹងត្រូវបានដោះលែងមួយរយៈពេលខ្លី បន្ទាប់ពីរយៈពេលមួយពាន់ឆ្នាំ និង បកស្រាយអំពីគោលបំណងនៃបល្ល័ង្កមួយធំពណ៌ស។

៧. ប្រាប់ពីមូលដ្ឋានគ្រឹះដែលអ្នករំពឹងទុកថាជាទិដ្ឋភាពមួយនៃការបង្កើតថ្មីដែលព្រះជាម្ចាស់បានបង្កើតឡើង។

## *សកម្មភាពក្នុងការសិក្សា*

១. ដើម្បីជាបង្អែកសម្រាប់មេរៀននេះ សូមអានគម្ពីរម៉ាថាយ ២៤ គម្ពីរម៉ាកុស ១៣ គម្ពីរលូកា២១ គម្ពីរ ១កូរិនថូស ១៥ គម្ពីរ១ថេស្សាឡូនិក៤:១៣-១៧, ២ថេស្សាឡូនិក២:១-១២, និង គម្ពីរវិវរណៈ១៩។ ត្រូវប្រាកដផងដែរថា អ្នកបានបើករក និង អាន បទគម្ពីរយោងដទៃទៀត ដែលបានផ្ដល់ជូននៅក្នុងមេរៀន។ ធ្វើការសិក្សាមេរៀន និង ការប្រឡងផ្ទាល់ខ្លួន ដូចធម្មតា។

២. បន្ទាប់ពីអ្នកបានធ្វើការប្រឡងផ្ទាល់ខ្លួនរួចហើយ ចូររំឭកមេរៀនទី៨ ដល់ទី១០ (ជំពូកទី៣ឡើងវិញ)។ បន្ទាប់មកធ្វើ*ការប្រឡងជំពូកទីបី ។*

## *ពាក្យសំខាន់ៗ*

| | | |
|---|---|---|
| គួរឲ្យស្អប់ខ្ពើម | បោះបង់ | ការកែលំអរ |
| ការប្រមាថ | ការបែកខ្ញែក | ឆ្នាំសប្ប័ទ |
| ការប្រឈមមុខ | ការផុតពូជ | ការប្រមាថវត្ថុពិសិដ្ឋ(សក្ការៈ) |
| ការបំពេញ | ដែលមិនវិនាស | ពេលកំណត់ |
| លើកជាព្រះ | ដែលអាចវិនាស | ជម្រះទោស |

# ក. សេចក្តីសង្ឃឹមដ៏មានពរ

**វត្ថុបំណងទី១.** *កំណត់និយមន័យសេចក្តីសង្ឃឹមដ៏មានពរ។*

នៅក្នុងសំបុត្ររបស់លោកសាវ័កប៉ុលទៅកាន់លោកទីតុស លោកថ្លែងថាដំណឹងល្អនៃព្រះគុណរបស់ព្រះជាម្ចាស់បានលេចមកឯមនុស្សគ្រប់គ្នា។ សំបុត្រនោះបានចោទជាចំណោទទៅកាន់ពួកគេជាមួយនឹងជម្រើសខាងឯសីលធម៌ ថាតើពួកគេនឹងនិយាយថា *ទេ* ទៅកាន់អំពើមិនបរិសុទ្ធ និង ចំណង់របស់លោកីយ៍ ហើយបែរមករស់នៅក្នុងជីវិតដែលចេះគ្រប់គ្រងខ្លួនឯង និង គោរពកោតខ្លាចព្រះជាម្ចាស់នៅក្នុងពេលបច្ចុប្បន្ននេះ នៅពេលដែលពួកគេកំពុងរង់ចាំ*សេចក្តីសង្ឃឹមដ៏មានពរ* ដែរឬអត់។ លោកបានមានប្រសាសន៍ថា សេចក្តីសង្ឃឹមដ៏មានពរនោះ គឺជាការបង្ហាញប្រកបដោយសិរីរុងរឿង របស់ព្រះជាម្ចាស់ដ៏ធំអស្ចារ្យរបស់យើង និង ព្រះអង្គសង្គ្រោះព្រះយេស៊ូគ្រិស្ត (គម្ពីរទីតុស ២:១១-១៤)។ ការបើកបង្ហាញរបស់ទ្រង់ ក៏នឹងនាំមកនូវការបំផ្លិចបំផ្លាញសម្រាប់អំណាចទាំងអស់ដែលទាស់នឹងព្រះជាម្ចាស់។ នៅពេលដែលយើងចាប់ផ្តើមសិក្សា "រឿងចុងក្រោយ" ឬ ព្រឹត្តិការណ៍គ្រាចុងក្រោយ យើងនឹងបង្វែរការយកចិត្តទុកដាក់របស់យើងទៅលើសេចក្តីសង្ឃឹមដ៏មានពររបស់អ្នកជឿជាមុនសិន។

នៅប៉ុន្មានម៉ោងចុងក្រោយ មុនពេលដែលទ្រង់សុគត ព្រះអម្ចាស់នៃយើងទ្រង់បានបង្ហាញទៅកាន់ពួកសាវ័កទាំង១២នាក់ អំពីមូលដ្ឋានគ្រឹះសម្រាប់សេចក្តីសង្ឃឹមរបស់អ្នកជឿ។ ទ្រង់បានមានព្រះបន្ទូលអំពីដំណាក់របស់ព្រះវរបិតាទ្រង់ ដែលមានបន្ទប់យ៉ាងច្រើន។ ទ្រង់បានប្រាប់ទៅពួកគេ ថាទ្រង់ចាកចេញទៅដើម្បីរៀបចំកន្លែងសម្រាប់ពួកគេ (និងសម្រាប់អស់អ្នកដែលជឿលើទ្រង់)។ ទ្រង់ក៏បាន ធានាប្រាប់ពួកគេថា ពិតដូចជាការចាកចេញរបស់ទ្រង់ ទ្រង់ក៏នឹងយាងត្រឡប់មកវិញដើម្បីយកពួកគេទៅរស់នៅរួមជាមួយទ្រង់ផងដែរ (គម្ពីរយ៉ូហាន ១៤:១-៣)។

ព្រះបន្ទូលនៃក្តីសង្ឃឹមនេះ ត្រូវបានបញ្ជាក់បន្ថែមដោយទេវតាដែលបានលេចមកក្រោយពេលព្រះយេស៊ូទ្រង់បានយាងត្រឡប់ទៅឯស្ថានបរមសុខវិញ។ លោកបានថ្លែងថា៖ "ព្រះយេស៊ូនោះ ព្រះជាម្ចាស់បានលើកពីកណ្តាលចំណោមអ្នករាល់គ្នា ឡើងទៅស្ថានបរមសុខហើយ ព្រះអង្គនឹងយាងត្រឡប់មកវិញតាមរបៀបដូចដែលអ្នករាល់គ្នាបានឃើញទ្រង់យាងឡើងទៅស្ថានបរមសុខដែរ"(គម្ពីរកិច្ចការ ១:១១)។ លោកសាវ័កប៉ុល បានប្រកាសឡើង ដោយមានការបើកសម្តែងពីព្រះជាម្ចាស់ថា អ្នកជឿរង់ចាំ "ការប្រោសលោះ" រូបកាយរបស់គេយ៉ាងអន្ទះសារ (គម្ពីររ៉ូម ៨:២៣) ដែលរូបកាយនោះនឹងផ្លាស់ប្តូរនៅពេលព្រះអម្ចាស់ព្រះយេស៊ូគ្រិស្តបង្ហាញអង្គទ្រង់មក (គម្ពីរភីលីព ៣:២០-២១)

បទគម្ពីរបង្ហាញថា ការយាងមករបស់ព្រះអម្ចាស់ រួមមានពីរទិដ្ឋភាព ៖ ទី១) ការយាងមក*សម្រាប់* អ្នកជឿ និង ទី២) ការយាងមក*ជាមួយ* ពួកគេ(អ្នកជឿ)។ ការយាងមករបស់ទ្រង់*សម្រាប់* អ្នកជឿគឺត្រូវបានហៅថា "ការឆក់ឡើង(ការលើកឡើង)" ហើយការយាងមករបស់ទ្រង់*ជាមួយ* ពួកគេគឺហៅថា ការបើកសម្តែង។ ស្របពេលដែលយើងអធិប្បាយរឿងរ៉ាវ នៃព្រឹត្តិការណ៍នាគ្រាចុងក្រោយ យើងត្រូវពិភាក្សាគ្នាអំពីព្រឹត្តិការណ៍ទាំងពីរនេះ។ ដំបូង ចូរយើងពិចារណាអំពីការឆក់ឡើង និង រង្វាន់របស់អ្នកជឿ ហើយបន្ទាប់មកអំពីទំនាក់ទំនងនៃរឿងទាំងនេះជាមួយនឹងព្រឹត្តិការណ៍ផ្សេងទៀត។

## *លំហាត់អនុវត្តន៍*

១ (ចូរជ្រើសរើសចម្លើយដែលល្អបំផុត)។ *សេចក្ដីសង្ឃឹមដ៏មានពរ* គឺសំដៅទៅលើ

ក) ការបើកសម្ដែងរបស់ព្រះគ្រិស្ដ នៅពេលដែលទ្រង់យាងមក *ជាមួយ* មនុស្សរបស់ទ្រង់។

ខ) ការឆក់អ្នកជឿឡើងទៅ នៅពេលដែលព្រះគ្រិស្ដយាងមក *សម្រាប់* ពួកគេ។

គ) ព្រឹត្តិការណ៍នាគ្រាចុងក្រោយទាំងអស់។

## ការឆក់អ្នកជឿឡើងទៅ

នៅពេលព្រះជាម្ចាស់ ជាមួយនឹងប្រាជ្ញាញាណជាក្សត្ររបស់ទ្រង់ បានកំណត់ថាកិច្ចការនៃការចែកចាយដំណឹងល្អបានសម្រេចពេញបរិបូរណ៍ហើយ ទ្រង់នឹងចាប់ផ្ដើម*ការជម្រះទោស* (ជាពេលមួយដែលអ្វីម្យ៉ាងត្រូវបានធ្វើឲ្យពេញលេញ និង ល្អឥតខ្ចោះ) នៅក្នុងផែនការរបស់ទ្រង់។

## *លំហាត់អនុវត្តន៍*

២ ចូរប្រៀបធៀមគម្ពីរម៉ាថាយ ២៤:១៤ ជាមួយនឹង គម្ពីរម៉ាថាយ ២៤:៣៦។ យោងទៅតាមខគម្ពីរទាំងនេះ តើយើងអាចដឹងអ្វីខ្លះ អំពីគ្រាដែលព្រះយេស៊ូយាងត្រឡប់មកសម្រាប់អស់អ្នកដែលជារាស្ត្ររបស់ទ្រង់?

..........................................................................................................................

នៅក្នុងគម្ពីរ១ថេស្សាឡូនិក ៤:១៧ យើងឃើញថា អ្នកជឿនឹងត្រូវបាន "លើកឡើង" (ឆក់យក) ទៅជួបព្រះអម្ចាស់នៅទីអាកាស ហើយត្រូវនាំទៅទីកន្លែងស្នាក់នៅ ដូចដែលបានសន្យានៅក្នុងគម្ពីរយ៉ូហាន ១៤:១-៣ ។ នៅក្នុងគម្ពីរ១កូរិនថូស ១៥:៥០-៥២ លោកប៉ូលបានបង្ហាញថា រូបកាយសាច់ឈាមរបស់អ្នកជឿទាំងអស់នឹងត្រូវបានផ្លាស់ប្ដូរ ស្របពេលដែលរូបកាយដែលអាចស្លាប់របស់ពួកគេ ត្រូវបានប្រែមួយរំពេច ហើយត្រូវបានត្រៀមសម្រាប់ស្ថានបរមសុខ។ ព្រឹត្តិការណ៍នេះ នឹងកើតឡើងភ្លាមៗ។ ទោះបីជាអ្នកជឿនៅកន្លែងក៏ណាដោយ ពួកគេនឹងត្រូវបាន "លើកឡើង" ភ្លាមៗ។ ព្រះគម្ពីរបានប្រៀបធៀបព្រឹត្តិការណ៍ភ្លាមៗនេះ ទៅនឹងការចូលលួចរបស់ចោរនៅពេលយប់ (គម្ពីរ១ថេស្សាឡូនិក ៥:២)។

សារបន្ទូលសម្រាប់អ្នកជឿគឺពិតយ៉ាងដូច្នេះថា៖ ពួកគេត្រូវតែប្រុងប្រយ័ត្ន និង គ្រប់គ្រងខ្លួនឯង នៅពេលដែលពួកគេរស់ពីមួយថ្ងៃទៅមួយថ្ងៃ ត្រូវដឹងថាការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ នឹងធ្លាក់មកលើអស់អ្នកបដិសេធការប្រទានសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ (គម្ពីរ១ថេស្សាឡូនិក ៥:១-១១)។ ដូច្នេះសេចក្ដីសង្ឃឹមរបស់អ្នកជឿគឺថា ១) ការប្រោសលោះឲ្យផុតពីព្រះពិរោធរបស់ព្រះជាម្ចាស់ដែលនឹងមកដល់ ២) អភ័យឯកសិទ្ធិ ក្នុងការមើលឃើញព្រះអម្ចាស់របស់ពួកគេ និង ៣) ត្រូវបានធ្វើឲ្យបានដូចជាទ្រង់ (គម្ពីរ១យ៉ូហាន ៣:២)។

## *លំហាត់អនុវត្តន៍*

៣ ចូរអានគម្ពីរ១ថេស្សាឡូនិក ៤:១៣-១៧ ហើយបំពេញចន្លោះបន្ទាត់ដើម្បីបង្គ្រប់ប្រយោគទាំងនេះ។

ក) អ្នកជឿពីរប្រភេទដែលនឹងត្រូវបានឆក់យកឡើងទៅ៖ ..........................................................
និង ..........................................................................................................................

ខ) សេចក្តីសង្ឃឹមរបស់អ្នកជឿ ទៅលើការយាងត្រឡប់មករបស់ព្រះអម្ចាស់ គឺផ្អែកទៅលើ................
..........................................................................................................................

គ) លោកប៉ូលបានបង្ហាញថា អ្នកមិនជឿទួញសោក ដោយព្រោះតែពួកគេគ្មាន..............................
.....................................................................ទៅលើការប្រោសរូបកាយឲ្យរស់ឡើងវិញ និង ជីវិតអស់កល្បជានិច្ច។

---

ការសិក្សាស៊ីជម្រៅមួយទៅលើគម្ពីរ១កូរិនថូស ១៥:៥០-៥៤ បង្ហាញថា នឹងមានការផ្លាស់ប្តូរមួយចំនួនកើតឡើង ទៅក្នុងពេលនៃការឆក់យកអ្នកជឿឡើងទៅ។ នៅក្នុងពេលដែលមានការឆក់យកឡើងទៅ អ្នកជឿដែលកំពុងមានជីវិតរស់នៅឡើង នឹងផ្លាស់ប្តូរពីភាពសាច់ឈាមដែលអាចស្លាប់បាន ទៅជាមានភាពអមតៈ ។ នេះមានន័យថា ពួកគេនឹងមិនអាចស្លាប់បាននោះទេ។ អ្នកជឿដែលបានស្លាប់នៅក្នុងព្រះគ្រិស្តនឹងត្រូវបានប្រោសឲ្យមានជីវិតរស់ជាមុនសិន ហើយបន្ទាប់មកពួកគេនឹងត្រូវបានផ្លាស់ប្តូរពី "ភាពដែលអាចវិនាស" (ដែលអាចផុយរលួយ ឬ កំទេច) ទៅជាមាន "ភាពមិនអាចវិនាស" (ដែលនឹងមិនផុយរលួយ) វិញ។ ដោយសារតែសាច់ និង ឈាមដែលជារូបកាយខាងឯសាច់ឈាមរបស់យើងបច្ចុប្បន្ន មិនអាចទទួលស្នងព្រះរាជ្យរបស់ព្រះជាម្ចាស់បាន អ្វីដែលត្រូវធ្វើនោះគឺថាពួកគេនឹងត្រូវបានផ្លាស់ប្តូរឲ្យមានរូបកាយដែលមាន*សិរីរុងរឿង* ។ យើងមិនយល់អ្វីគ្រប់យ៉ាងអំពីរូបកាយដែលមានសិរីរុងរឿងទាំងនេះទេ ប៉ុន្តែយើងដឹងថារូបកាយទាំងអស់នោះ នឹងមិនទទួលការឈឺចាប់ មានជំងឺ ឬស្លាប់ទៀតទេ ហើយពួកគេនឹងរស់រានមានជីវិតអស់កល្បជានិច្ច។

ការឆក់យកនឹងកើតឡើងភ្លាមៗ ហើយគ្មាននរណាម្នាក់ដឹងពីពេលវេលាជាក់លាក់ លើកលែងតែព្រះជាម្ចាស់ យើងក៏ទទួលបានតម្រុយខ្លះអំពីពេលវេលាដែលការនោះនឹងកើតឡើង។ ព្រះយេស៊ូបានមានព្រះបន្ទូលថា នឹងមានទីសំគាល់ ឬ ភាពចលាចលនៅឯនគរស្ថានសួគ៌ ដែលអាចនឹងបង្កឲ្យមានភាពតានតឹង ឬ ទុក្ខព្រួយ នៅក្នុងប្រជាជាតិជាច្រើន។ លើសពីនេះទៅទៀត នឹងមានគ្រោះទុរភិក្ស ជំងឺ និង សង្គ្រាមកើតឡើង ថែមពីលើទីសំគាល់ដែលមាននៅឯស្ថានសួគ៌ (សូមមើលគម្ពីរលូកា ២១:១០,២៥-២៨)។ ព្រឹត្តិការណ៍ទាំងនេះ គឺគ្រាន់តែជាការផ្តល់សញ្ញាអំពីការ ខិតចូលជិតទៅដល់ទីបញ្ចប់។ អ្នកជឿបានដឹងតាមរយៈការទាំងនេះ ថា ការប្រួបរួមរបស់ពួកគេជាមួយនឹងព្រះគ្រិស្តក៏ជិតមកដល់ ក៏ដូចជា *ការប្រួបរួមគ្នាសាជាថ្មី* ជាមួយមិត្តជាទីស្រឡាញ់ និង សាច់ញាតិដែលបានទៅនៅជាមួយព្រះជាម្ចាស់មុននោះផងដែរ។

# *លំហាត់អនុវត្តន៍*

៤ ចូរបកស្រាយយ៉ាងខ្លី អំពីអ្វីដែលនឹងកើតឡើងចំពោះរូបកាយសាច់ឈាមរបស់អ្នកដែលកំពុងរស់ និង អ្នកដែលបានស្លាប់ទៅ នៅក្នុងពេលដែលមានការឆក់យកឡើងទៅ។

.......................................................................................................................................

## រង្វាន់របស់អ្នកជឿ

មានឯកសារយោងមួយចំនួននៅក្នុងព្រះគម្ពីរ បង្ហាញថាអ្នកជឿនឹងទទួលបានរង្វាន់ដោយផ្អែកទៅលើឥរិយាបថគ្រិស្តបរិស័ទរបស់ពួកគេ (សូមមើលគម្ពីរម៉ាថាយ ១៦:២៧ គម្ពីរ២យ៉ូហាន ៥៨ គម្ពីរវិវរណៈ ២២:១២)។ លោកប៉ូលបានមានប្រសាសន៍ទៅកាន់សមាជិកនៃក្រុមជំនុំក្រុងកូរិនថូសថា៖ "ដ្បិតយើងទាំងអស់គ្នានឹងត្រូវទៅឈរនៅមុខទីកាត់ក្តីរបស់ព្រះគ្រិស្ត" (គម្ពីរ២កូរិនថូស ៥:១០)។ ពាក្យថា *ទីកាត់ក្តី* គឺបានបកប្រែមកពីពាក្យ *ប៊ីម៉ា* (Bema) ហើយត្រូវបានគេស្គាល់យ៉ាងច្បាស់ថា *វេទិកាពិនិត្យពិច័យរង្វាន់* ។ ការបង្ហាញដ៏ល្អមួយអំពីវេទិកានេះគឺថា វេទិកាដូចទៅនឹងវេទិកាដែលចៅក្រមក្នុងការប្រកួតអូឡាំពិក ឈរពិនិត្យពិច័យការប្រកួត ដើម្បីឲ្យពួកគេអាចផ្តល់រង្វាន់សម្រាប់អ្នកឈ្នះ។ គោលបំណងនៃការពិនិត្យពិច័យនេះគឺ ដើម្បីឲ្យអ្នកជឿគ្រប់គ្នា មកប្រាប់អំពីរឿងរ៉ាវរបស់ពួកគេទៅកាន់ព្រះជាម្ចាស់ (គម្ពីររ៉ូម ១៤:១០-១២)។

ការវិនិច្ឆ័យទោសរបស់យើងដោយព្រះជាម្ចាស់ គឺជាការពិនិត្យពិច័យអំពីការបម្រើជាគ្រិស្តបរិស័ទរបស់យើង។ ការនោះមិនមែនជាស្រេចទៅលើ *បរិមាណ* នៃកិច្ចការដែលយើងបានធ្វើនោះទេ ប៉ុន្តែគឺទៅលើ *គុណភាព* នៃអ្វីដែលយើងបានធ្វើសម្រាប់ព្រះជាម្ចាស់ ដែលនឹងត្រូវបានពិនិត្យឡើងវិញ។ តើមានអ្វីខ្លះដែលជាការជំរុញការបម្រើរបស់យើង។ តើវាត្រូវបានធ្វើឡើងថ្វាយទៅកាន់ទ្រង់ដោយមិនគិតពីខ្លួនឯង ឬក៏យើងបានបម្រើ គ្រាន់តែដើម្បីបង្វែរការចាប់អារម្មណ៍មកកាន់ទេពកោសល្យ សមត្ថភាព និង ធនធានរបស់យើងនោះទេ? ព្រះគម្ពីរបានបង្ហាញយ៉ាងច្បាស់ៗ ថា គុណភាពនៃកិច្ចការរបស់យើង នឹងត្រូវបានពិនិត្យពិច័យ ហើយការបម្រើដែលឆ្លងផុតការល្បងល ជាប់ជា *ការបម្រើដែលមានគុណភាព* នឹងត្រូវទទួលបានរង្វាន់។ ការបម្រើដែលត្រូវបានជំរុញដោយភាពអាត្មានិយម និង អំណួត នឹងមិនត្រូវទទួលបានរង្វាន់នោះទេ(សូមមើលនៅក្នុង គម្ពីរ១កូរិនថូស ៣:១១-១៥)។

ទោះបីជា ពេលវេលានៃការពិនិត្យពិច័យ មិនត្រូវបាននរណាម្នាក់ដឹងជាក់ច្បាស់ ក៏មានអ្នកប្រាជ្ញខាងព្រះគម្ពីរខ្លះ ជឿថា គ្រានោះនឹងកើតឡើងបន្ទាប់ពីការឆក់ឡើងទៅ។ ស្របពេលអស់អ្នកដែលបដិសេធនឹងការសង្គ្រោះរបស់ព្រះជាម្ចាស់ កំពុងតែឆ្លងកាត់គ្រាមួយដែលពេញដោយអំពើទុច្ចរិត ទុក្ខព្រួយ និង ភាពចលាចល មិនដែលធ្លាប់ឃើញពីមុនមកនៅលើផែនដី អ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះអម្ចាស់នឹងត្រូវបានតម្កើងកិត្តិយស នៅក្នុងព្រះវត្តមានរបស់ទ្រង់។

## លំហាត់អនុវត្តន៍

៥ (ចូរជ្រើសរើសចម្លើយដែលល្អបំផុត)។ បទគម្ពីរបង្រៀនយើងថា អ្នកជឿគ្រប់គ្នា នឹងត្រូវបានរៀបរាប់រឿងរ៉ាវនៃការបម្រើរបស់ផងគេទៅកាន់ព្រះជាម្ចាស់ និងបង្រៀនថា មនុស្សគ្រប់គ្នានឹង

ក) ទទួលបានរង្វាន់ដូចគ្នា ទោះបីជាការបម្រើរបស់ពួកគេ ធំ ឬ តូចប៉ុនណាក៏ដោយ។

ខ) ទទួលបានរង្វាន់មួយដែលផ្អែកទៅលើទាំង បរិមាណ និង គុណភាព នៃការបម្រើរបស់ពួកគេ។

គ) ទទួលបានរង្វាន់មួយដែលផ្អែកលើបំណងចិត្ត ឬ គុណភាពនៃការបម្រើរបស់គេ។

ឃ) បើទោះជារង្វាន់ ឬ ការដាក់ទោសនោះក៏ដោយ។

៦ ដោយឆ្លើយដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក ចូរបកស្រាយខ្លីៗអំពីឃ្លានីមួយៗនៅខាងក្រោមនេះ។

ក) រូបកាយដែលមានសិរីរុងរឿងរបស់អ្នកជឿ។

ខ) ការបើកសម្តែងរបស់ព្រះយេស៊ូគ្រិស្ត

គ) ការឆក់យកឡើងទៅ

ឃ) សេចក្តីសង្ឃឹមដ៏មានពរ

ង) ទីកាត់ក្តីរបស់ព្រះគ្រិស្ត

## ខ. គ្រាមហាវេទនា

នៅក្នុងការថ្លែងព្រះបន្ទូលនៅភ្នំអូលីវ ដែលមានកត់ត្រានៅក្នុងគម្ពីរម៉ាថាយ ២៤ គម្ពីរម៉ាកុស ១៣ និងគម្ពីរលូកា ២១ ព្រះយេស៊ូបានមានបន្ទូលតបទៅនឹងសំណួរដែលពួកសាវ័កចោទសួរថា៖ តើពេលណាទើបព្រះវិហារក្នុងពេលបច្ចុប្បន្ននេះ នឹងត្រូវបានបំផ្លាញ? និង ២) តើនឹងមានអ្វី ជាសញ្ញាសំគាល់អំពីការយាងមករបស់ទ្រង់ និង អំពីគ្រាចុងក្រោយ?

ចម្លើយរបស់ព្រះយេស៊ូ សម្រាប់សំណួរដ៏សំខាន់ទាំងពីរសំណួរនេះ គឺត្រូវបានច្របល់ចូលលាយគ្នាដែលធ្វើឲ្យមានការលំបាកក្នុងការកំណត់ថាតើទិដ្ឋភាពណានៃចម្លើយរបស់ទ្រង់សំដៅទៅលើការបំផ្លាញព្រះវិហារ និង ការខ្ចាត់ខ្ចាយ (ការបែកខ្ញែក) របស់ពួកយូដា ជាព្រឹត្តិការណ៍មួយដែលនឹងកើតឡើងឆាប់ៗ និង ចម្លើយសំដៅទៅលើសញ្ញាសំគាល់ដែលនឹងមកមុនការយាងត្រឡប់របស់ព្រះយេស៊ូ នៅក្នុង "គ្រាចុងក្រោយ" ។

យើងទទួលបានជំនួយដ៏អស្ចារ្យមួយ នៅក្នុងការស្វែងយល់អំពីចម្លើយរបស់ព្រះយេស៊ូ ដោយទ្រង់បានមានព្រះបន្ទូលសំដៅទៅកាន់ទំនាយរបស់លោកដានីយ៉ែល ដែលបានប្រាប់អំពីព្រឹត្តិការណ៍នៃគ្រាចុងក្រោយយ៉ាងជាក់លាក់ (គម្ពីរម៉ាថាយ ២៤:១៥)។ នៅក្នុងទំនាក់ទំនងជាមួយនឹងការណ៍នេះ យើងនឹងទទួលបានផលប្រយោជន៍ពីការរំឭកអំពីប្រវត្តិសាស្ត្ររបស់ពួកយូដា និង ទំនាក់ទំនងរបស់ពួកគេទៅនឹងព្រឹត្តិការណ៍ ដែលយើងកំពុងសិក្សានៅពេលនេះ។

ព្រះជាម្ចាស់នឹងប្រទានឲ្យយើងនូវ គម្រោងទូទៅមួយនៃព្រឹត្តិការណ៍នាថ្ងៃអនាគត ដែលទាក់ទងនឹង ពួកយូដា និង រាជធានីរបស់ពួកគេ គឺក្រុងយេរូសាឡឹម (គម្ពីរដានីយ៉ែល ៩:២៤-២៧)។ គម្រោងនេះគឺ ផ្តោតទៅលើ ការកំណត់ពេលវេលាមួយដែលរាប់បញ្ចូល ប្រវត្តិសាស្ត្ររបស់ពួកយូដា ក៏ដូចជាអនាគត របស់ពួកគេផងដែរ។ ចូរអានគម្ពីរដានីយ៉ែល ជំពូក៩ ដើម្បីត្រៀមសម្រាប់ការពិភាក្សារបស់យើងអំពី ព្រឹត្តិការណ៍ទាំងនេះ។

# សេចក្តីសង្គ្រោះមួយរបស់ពួកយូដា នៅក្នុងប្រវត្តិសាស្ត្រព្រះគម្ពីរ និង បទទំនាយ

**វត្ថុបំណងទី២.** *ពិភាក្សាថាតើ ព្រឹត្តិការណ៍នៃបទទំនាយណាខ្លះ នៅក្នុងគម្ពីរដានីយ៉ែលជំពូក ៩ និង អេម៉ុសជំពូក៩ បានកើតមានឡើងរួចទៅហើយ។*

## និមិត្តរបស់លោកដានីយ៉ែល

បទគម្ពីរបានប្រាប់យើងថា ដោយសារតែភាពបរាជ័យរបស់ប្រជាជនយូដា ក្នុងការប្រត្តិបត្តិថ្ងៃ សប្ប័ទនៅក្នុងទឹកដីរៀងរាល់ ប្រាំពីរឆ្នាំម្តង នោះព្រះជាម្ចាស់ដាក់បញ្ញត្តិឲ្យពួកគេរស់នៅក្នុងទឹកដីរបស់ សត្រូវរបស់គេរយៈពេល៧០ឆ្នាំ។ (ចូរប្រៀបធៀប គម្ពីរលេវីវិន័យ ២៥:២-៧ និង ២៦:១៤-១៦,៣១-៣៥ ជាមួយនឹង គម្ពីរ២របាក្សត្រ ៣៦:២១ សម្រាប់ការបកស្រាយ អំពីឆ្នាំសប្ប័ទ និង លទ្ធផលដែលនឹងកើត មានឡើងនៅពេលដែលមិនប្រតិបត្តិតាមថ្ងៃនេះ។) អ្វីដែលយើងចង់បញ្ជាក់គឺថា ក្នុងរយៈ៤៩០ឆ្នាំហើយ មនុស្សមិនបានបរាជ័យក្នុងការប្រកាន់ខ្ជាប់នូវការកំណត់របស់ឆ្នាំសប្ប័ទ។ គន្លឹះសំខាន់សម្រាប់ចូលទៅ កាន់បទទំនាយដ៏ខ្លីប៉ុន្តែមានសារៈសំខាន់យ៉ាងខ្លាំងនេះ គឺស្ថិតនៅជុំវិញរយៈពេល ប្រាំពីរឆ្នាំ ចិតសិបដង ឬ ចិតសិប "អាទិត្យ" នៃឆ្នាំ (មួយអាទិត្យនៃឆ្នាំស្មើ ៧ឆ្នាំ) ដែលមាននិយាយនៅក្នុងខ ២៤-២៧។

ប្រជាជាតិអ៊ីស្រាអែល បានទម្លាប់ខ្លួនទៅនឹងរាល់ "អាទិត្យ" នៃឆ្នាំ ជារៀងរាល់ ឆ្នាំទីប្រាំពីរ ដែលជា ឆ្នាំសប្ប័ទ នៃការសម្រាកនៃទឹកដី (គម្ពីរលេវីវិន័យ ២៥:៣-៤)។ បុណ្យខួបគំរប់ដ៏ធំនៃកំណែទម្រង់សង្គម និង សេដ្ឋកិច្ចគឺប្រារព្ធនៅរាល់ឆ្នាំទី៥០ ដែលយោងទៅតាម*អាទិត្យនៃឆ្នាំ* សំខាន់ៗជាច្រើននៃឆ្នាំនីមួយៗ គឺថាប្រាំពីរឆ្នាំ ប្រាំពីរដង ឬ ប្រាំពីរអាទិត្យនៃឆ្នាំ (សូមមើលនៅក្នុងគម្ពីរលេវីវិន័យ ២៥:៨-៩) ។ នៅក្នុងឆ្នាំ ទីហាសិបនេះ បំណុលទាំងអស់នឹងត្រូវបោះបង់ចោល ទាសករត្រូវដោះឲ្យមានសេរីភាព និង កម្មសិទ្ធិដីធ្លី នឹងត្រឡប់ទៅជារបស់ម្ចាស់ដើមវិញ។

## ចិតសិបអាទិត្យនៅក្នុងទស្សនវិស័យនៃការធ្វើបទទំនាយ

" ព្រះអង្គបានកំណត់ពេលប្រាំពីរឆ្នាំ (អាទិត្យនៃឆ្នាំ) ចិតសិបដង សំរាប់ប្រជាជន (ពួកយូដា) និងក្រុងដ៏វិសុទ្ធរបស់លោក [ក្រុងយេរូសាឡឹម] ។"

**គម្ពីរដានីយ៉ែល ៩:២៤-២៩**




(ចំណាំ៖ មួយអាទិត្យ =7ឆ្នាំ)

នេះពិតជាការចម្លែកណាស់ ដែលក្រោយពេលត្រូវបានជាប់ជាទាសកអស់រយៈពេលជិត៧០ឆ្នាំ ទេវតាមួយអង្គក៏នឹងត្រូវបានចាត់បញ្ជូនមកដើម្បីធ្វើការប្រាប់ទៅកាន់មនុស្សតាមរយៈលោកដានីយ៉ែល អំពីការចាប់ផ្ដើមនៅពេលវេលាថ្មីមួយដែលព្រះជាម្ចាស់ ដោះស្រាយបញ្ហាជាមួយនឹងពួកយូដា។ ដូចដែលយើងបានឃើញនៅក្នុងបទទំនាយរបស់លោកដានីយ៉ែលហើយថា ពេលវេលានេះ នឹងលាតសន្ធឹងឲ្យមានចំនួនឆ្នាំដូចទៅនឹងចំនួនដងដែលគេមិនគោរពតាមឆ្នាំសប្ប័ទដែរ ឬក៏ស្មើនឹង៤៩០ឆ្នាំ (នោះមានន័យថា ប្រាំពីរឆ្នាំ ចិតសិបដង)។ សូមយើងងាកមករំឭកយ៉ាងខ្លីៗ អំពីការពិតដែលបានផ្ដល់ឲ្យឃើញនៅក្នុងនិមិត្តរបស់លោកដានីយ៉ែល ហើយបន្ទាប់មកយើងមើលទៅលើការបកស្រាយនិមិត្តមួយនេះ។

១. បទទំនាយដែលទាក់ទងនឹងមនុស្សរបស់លោកដានីយ៉ែល គឺពួកយូដា និង ទីក្រុងវិសុទ្ធរបស់លោក គឺក្រុងយេរូសាឡឹម (ខ.២៤)។
២. បទទំនាយដែលមានរាប់បញ្ចូលរយៈពេលប្រាំពីរឆ្នាំចិតសិបដង ឬ ប្រាំពីរអាទិត្យ ចិតសិបដង ។ ការណ៍នេះបង្ហាញពីរយៈពេលចំនួន៤៩០ឆ្នាំ។
៣. សកម្មភាពដែលត្រូវសម្រេចឲ្យបាននៅក្នុងរយៈពេលនេះ រួមមានៈ
    ក. ការបញ្ចប់អំពើរំលង
    ខ. បញ្ឈប់ការប្រព្រឹត្តិអំពើបាប
    គ. ការលន់តួសម្រាប់ភាពមានបាប
    ឃ. ការចាក់ប្រេងអភិសេកសម្រាប់អ្នកដែលវិសុទ្ធជាងគេ (ឬ ព្រះដ៏វិសុទ្ធជាងគេ)
    ង. ការនាំមកនូវភាពសុចរិតដ៏អស់កល្បជានិច្ច។ (ខ.២៤)
៤. អំឡុងពេលដែលត្រូវបានរាប់បញ្ចូលដំបូងបំផុតគឺ ប្រាំពីរឆ្នាំ ប្រាំពីរដង (៤៩ឆ្នាំ) និង ប្រាំពីរឆ្នាំ ហុកសិបពីរដង (៤៣៤ ឆ្នាំ) ដែលបូកសរុបទាំងអស់គឺប្រាំពីរ ហុកសិបប្រាំបួនដង (៤៨៣ឆ្នាំ សូមមើលខ. ២៥)។
៥. ពេលវេលា*ចាប់ផ្ដើម* នៅចំណុចដ៏ជាក់លាក់មួយៈ ការថ្លែងប្រកាសពីបញ្ញត្តិនៅក្នុងគ្រាជួសជុល និង សង់ក្រុងយេរូសាឡឹមឡើងវិញ។
៦. រយៈពេលនៃការចាប់ផ្ដើមដំបូង បញ្ចប់ទៅជាមួយនឹងព្រឹត្តិការណ៍ដ៏ជាក់លាក់មួយៈ ការយាងមកដល់របស់លោកដែលគេចាក់ប្រេងអភិសេក និង ការដាក់យកជីវិតរបស់លោក មិនយូរប៉ុន្មានក្រោយមក(ខ.២៥ ដល់ ខ.២៦)
៧. ទស្សនវិស័យរបស់ស្ដេចពីរអង្គៈ លោកដែលត្រូវគេចាក់ប្រេងអភិសេក (ព្រះយេស៊ូ) និង ស្ដេចមួយដែលនឹងមក (អ្នកប្រឆាំងព្រះគ្រិស្ត,ពួកទទឹងនឹងព្រះគ្រិស្ទ) ដែលនឹងលើកគ្នាមកកំទេចទីក្រុង និងទីសក្ការៈ។
៨. បន្ទាប់មកនៅប្រាំពីរឆ្នាំ (មួយអាទិត្យរបស់)ឆ្នាំ ដែលផ្ដោតសំខាន់ទៅលើការដែល*ស្ដេចមួយអង្គដែលនឹងមកដល់* (អ្នកប្រឆាំងព្រះគ្រិស្ត) នឹងធ្វើការសន្យាជាមួយពួកយូដា។

ទោះជាយ៉ាងណាក្តី នៅពាក់កណ្តាលពេលប្រាំឆ្នាំនេះ មានន័យថាបីឆ្នាំកន្លះ ស្តេចដែលនឹងមកដល់តាមក្រោយនេះ នឹងក្បត់ពាក្យសន្យា ហើយថែមទាំងបញ្ឈប់រាល់សកម្មភាពសាសនាទាំងអស់របស់ពួកយូដា និង ធ្វើឲ្យមានភាពហិនហោច (បំផ្លាញ ធ្វើឲ្យអស់គ្មានសល់) នៅក្នុងព្រះវិហារ មុនពេលដែលសុគតទៅវិញ។

## *លំហាត់អនុវត្តន៍*

៧ ដោយផ្អែកទៅលើព័ត៌មានដែលទទួលបានពីខាងលើមក យើងអាចសន្និដ្ឋានបានថារយៈពេលដែលមាននៅក្នុងនិមិត្តរបស់លោកដានីយ៉ែល គឺផ្អែកទៅលើចំនួន នៃ

ក) រយៈពេលដែលពួកយូដាមិនបានប្រតិបត្តិតាម ឆ្នាំសប្ប័ទរបស់ពួកគេ។

ខ) ស្តេចដែលនឹងមកគ្រប់គ្រងលើពួកប្រជាជនយូដា។

គ) អាទិត្យនៅក្នុងមួយឆ្នាំ។

---

## ការបកស្រាយនិមិត្ត

យើងនឹងបន្ត ជាមួយនឹងការបកស្រាយនៃនិមិត្តដ៏អស្ចារ្យមួយនេះ ដែលចាប់ផ្តើមជាមួយនឹងគម្ពីរដានីយ៉ែល ៩:២៥៖

> ដូច្នេះ សូមជ្រាប ហើយយល់អត្ថន័យនេះចុះ! ចាប់ពីពេលព្រះអម្ចាស់មានព្រះបន្ទូល ស្តីអំពីការរៀបចំសង់ក្រុងយេរូសាឡឹមឡើងវិញ រហូតដល់ពេលស្តេចដែលជាព្រះមេស្ស៊ី*យាងមកដល់មានរយៈពេលប្រាំពីរឆ្នាំប្រាំពីរដង ហើយនៅប្រាំពីរឆ្នាំហុកសិបពីរដងទៀត គេនឹងសង់ទីក្រុង និងកំពែងឡើងវិញ តែគ្រានោះជាគ្រាមួយដ៏សែនវេទនា។ លុះរយៈពេលប្រាំពីរឆ្នាំហុកសិបពីរដងនោះកន្លងផុតទៅ លោកដែលគេចាក់ប្រេងអភិសេក នឹងត្រូវគេដកជីវិត គ្មាននរណាការពារលោកទេ។ ប្រជាជាតិរបស់ស្តេចមួយអង្គនឹងលើកគ្នាមកកំទេចទីក្រុង និងទីសក្ការៈ។ នៅទីបញ្ចប់ ស្តេចនោះ នឹងទទួលទោសពីព្រះជាម្ចាស់។ ប៉ុន្តែ ស្តេចនោះនឹងបន្តធ្វើសឹកបំផ្លិចបំផ្លាញ រហូតដល់សោយទិវង្គតដូចបានកំណត់ទុក។ ( ខ២៥ ដល់ ២៦)

ចូរសំគាល់មើលថា បទបញ្ជាដើម្បីឲ្យជួសជុល និង សាងសង់ក្រុងយេរូសាឡឹមឡើងវិញ ត្រូវបានផ្តល់មក "នៅឆ្នាំទីម្ភៃ នៃរជ្ជកាលព្រះចៅអើថាស៊ើកសេស" (គម្ពីរនេហេមា ២:១-៨)។ការត្រួតពិនិត្យមើលឡើងវិញយ៉ាងប្រុងប្រយ័ត្ន ទៅលើកំណត់ត្រាប្រវត្តិសាស្ត្រ ដែលបង្ហាញឲ្យឃើញពីកាលបរិច្ឆេទនៅក្នុងឆ្នាំ៤៤៥ មុខគ.ស អំពីការដាក់បញ្ជានេះ។ ទីក្រុងពិតជាបានសាងសង់ឡើងវិញពិតមែននៅក្នុងពេលដែលកំពុងមានបញ្ហា។ បន្ទាប់ពី ៤៣៤ឆ្នាំក្រោយមកទៀត ព្រះដែលត្រូវគេចាក់ប្រេងអភិសេកក៏បានលេចឡើងមកយ៉ាងជាក់ច្បាស់ទៅតាមបទទំនាយមែន។ អ្នកប្រាជ្ញខាងឯព្រះគម្ពីរបានគណនាយ៉ាងប្រុងប្រយ័ត្ន ហើយឃើញថា ៤៨៣ឆ្នាំគត់ បន្ទាប់ពីការដាក់បញ្ជារបស់ស្តេចអើថាស៊ើកសេស ព្រះយេស៊ូដែលជាអ្នកដែលត្រូវគេចាក់ប្រេងអភិសេក បានធ្វើការយាងចេញដោយភាពជោគជ័យ ទៅក្នុងក្រុងយេរូសាឡឹម

នៅគ្រាចុងក្រោយនៃព័ន្ធកិច្ចលើផែនដីរបស់ទ្រង់ (គម្ពីរលូកា ១៩:២៨-៣៨)។ បន្ទាប់មក មិនបានប៉ុន្មានថ្ងៃក្រោយមក ទ្រង់ក៏ត្រូវបានគេធ្វើគុត នៅក្នុងព្រឹត្តិការណ៍ដែលគេឆ្កាងទ្រង់។

ក្រោយមកទៀត នៅក្នុងនិមិត្តរបស់លោកដានីយ៉ែល មានទេវតាបានមកប្រាប់លោកថា មនុស្សរបស់ស្ដេចដែលនឹងមកតាមក្រោយនឹងបំផ្លាញទីក្រុង និង ទីសក្ការៈ នៅក្រោយពេលព្រះដែលត្រូវគេចាក់ប្រេងអភិសេកត្រូវបានគេធ្វើគុត (ខ.២៦)។ ទិដ្ឋភាពមួយនេះនៃបទទំនាយត្រូវបានសម្រេចនៅក្នុងឆ្នាំ៧០ គ.ស នៅពេលដែលពួកទាហានរ៉ូម៉ាំងបំផ្លាញក្រុងយេរូសាឡឹម កំទេចកំពែងក្រុង ហើយដុតទីសក្ការ (ព្រះវិហារ) ហើយបន្ទាប់មកវាយកំទេចទាំងថ្មដែលសាងសង់ព្រះវិហារនោះទៀតផង (គម្ពីរម៉ាថាយ ២៤:២)។ នៅក្នុងពេលនេះ ប្រទេសរបស់ពួកយូដា ដែលហៅថាអ៊ីស្រាអែលនេះ ក៏លែងមានវត្តមានជាប្រទេសដែលមានអធិបតេយ្យភាព (គ្រប់គ្រងដឹកនាំដោយខ្លួន) ទៀតហើយ។ ប្រជាជនរបស់សាសន៍នេះបានខ្ចាត់ខ្ចាយទៅដល់ចុងបំផុតនៃផែនដី ហើយគម្រោងការដ៏យូរអង្វែងដែលព្រះជាម្ចាស់បានមានព្រះបន្ទូលប្រាប់ទុកមុន (គម្ពីរដានីយ៉ែល ៩:២៤) ក៏ហាក់បីដូចជាត្រូវផ្អាកត្រឹមនោះដែរ។

ព្រឹត្តិការណ៍នៅប្រាំពីរឆ្នាំ ឬ អាទិត្យទីចិតសិបនៃឆ្នាំ ដែលនៅក្នុងនិមិត្តរបស់លោកដានីយ៉ែលមិនទាន់បានកើតឡើងនៅឡើយទេ។ រយៈពេលចុងក្រោយនៅក្នុងផែនការរបស់ព្រះជាម្ចាស់សម្រាប់ជាតិសាសន៍យូដានេះហើយ ដែលយើងត្រូវខ្វាយខ្វល់ជាពិសេស ទាក់ទងទៅនឹងគ្រាចុងក្រោយ។ ដូច្នេះ យើងត្រូវធ្វើការសិក្សា អ្វីដែលបានកើតឡើង ដែលធ្វើឲ្យខូចខាតគម្រោងពេលវេលាដែលព្រះជាម្ចាស់បានបង្កើតឡើង។  យើងនឹងចាប់ផ្ដើម ជាមួយនឹងថ្ងៃដំបូងបង្អស់ របស់សាសន៍យូដា។

ព្រះជាម្ចាស់បានបង្ហាញយ៉ាងខ្លីហើយច្បាស់ៗ ទៅកាន់សាសន៍អ៊ីស្រាអែលនៅពេលដែលគេចូលទៅក្នុងទឹកដីសន្យាថា *ការស្ដាប់បង្គាប់* តាមក្រឹត្យវិន័យរបស់ទ្រង់នឹងនាំមកនូវប្រយោជន៍ (សូមមើលគម្ពីរទុតិយកថា ២៨:១-១៤)។ ទ្រង់ក៏បានមានព្រះបន្ទូលយ៉ាងច្បាស់ៗ អំពីការអាក្រក់ដែលនឹងតាមជាប់*ការមិនបង្គាប់ស្ដាប់* របស់ប្រជារាស្ត្រទ្រង់ (គម្ពីរលេវីវិន័យ ២៦:១៤-៤៥ គម្ពីរទុតិយកថា ២៨:១៥-៦៨)។ ព្រះគម្ពីរបានបង្ហាញថា ដោយសារតែការមិនស្ដាប់បង្គាប់របស់ពួកគេ និង ភាពពេញដោយបាបដែលហាក់ដូចជាមិនអាចព្យាបាលបានរបស់ពួកគេនោះ ចុងក្រោយព្រះជាម្ចាស់បានអនុញ្ញាតឲ្យប្រជារាស្ត្ររបស់ទ្រង់ត្រូវបានខ្ចាត់ខ្ចាយ (បែកខ្ញែង ឬ បណ្ដេញចេញ) ពីទឹកដីរបស់ពួកគេ។ បន្ទាប់ទ្រង់ធ្វើឲ្យទឹកដីនោះ ស្ងាត់សូន្យគ្មាននរណាម្នាក់រស់នៅ (គម្ពីរអេសាយ ៦:១១-១២; ១៧:៩; ៦៤:១០)។ នៅមុននេះ ការជាប់ជាទាសកររយៈពេល៧០ឆ្នាំមិនមានប្រយោជន៍ក្នុងការនាំយកប្រជារាស្ត្ររបស់ព្រះជាម្ចាស់កាន់ទ្រង់នោះទេ។ ដូច្នេះ ជាមួយនឹងការខ្ចាត់ខ្ចាយដែលកើតឡើងដោយការកាន់កាប់របស់ពួករ៉ូម៉ាំង ពួកសាសន៍យូដាបានក្លាយខ្លួនជា "ពួកវង្វេង" ហើយពួកគេរងទុក្ខសោកដែលគ្មាននរណាអាចប្រាប់បាន នៅពេលដែលពួកគេបានស្វែងរកកន្លែងដើម្បីជ្រកឲ្យផុតពីភាពកាចសាហាវរបស់សាសន៍ដទៃ។

ដូច្នេះ សាសន៍អ៊ីស្រាអែលជាសាសន៍ដែលព្រះជ្រើសរើស ត្រូវបានបណ្ដេញចេញពីទឹកដីសន្យាមួយរយៈ។ ព្រះជាម្ចាស់ដែលមានក្ដីស្រឡាញ់ និង ក្ដីមេត្តា បានបង្ហញថា ទ្រង់នឹងមិនបោះបង់ប្រជារាស្ត្ររបស់ទ្រង់ចោលទាំងស្រុងនោះទេ (គម្ពីរលេវីវិន័យ ២៦:៤៣-៤៥) ប៉ុន្តែទ្រង់នឹងត្រាស់ហៅពួកគេពីចុងបំផុតនៃផែនដីមកវិញ (គម្ពីរអេសាយ ១១:១១-១២)។ ទ្រង់នឹងប្រើប្រាស់មធ្យោបាយគ្រប់បែបយ៉ាងដើម្បីប្រមូលពួកគេមកវិញ និង ដើម្បីដកពួកគេចេញពីផ្ទះបណ្ដោះអាសន្នរបស់ពួកគេ ហើយនាំពួកគេទៅ

ទឹកដីដែលទ្រង់បានប្រទានទៅកាន់ "ឪពុក" របស់ពួកគេ គឺលោកអប្រាហាំដើម្បីឲ្យក្លាយជាកម្មសិទ្ធិរបស់គេអស់កល្បជានិច្ច (គម្ពីរយេរេមា ១៦:១៤-១៦)។

## *លំហាត់អនុវត្តន៍*

៨ តើព្រឹត្តិការណ៍ (នៃការសម្រេចបទទំនាយរបស់លោកដានីយ៉ែល) អ្វីបានកើតឡើង និង កំណត់ទីបញ្ចប់របស់សាសន៍យូដា ដែលធ្វើឲ្យប្រជាជនបានខ្ចាត់ខ្ចាយទៅដល់ចុងបំផុតនៃផែនដី។

..........................................................................................................................................

## ការត្រឡប់មកអ៊ីស្រាអែលវិញ

វាពិតជាគួរឲ្យចាប់អារម្មណ៍ណាស់ ដែលនៅដើមសតវត្សថ្មីនេះ បន្ទាប់មានការបៀតបៀនយ៉ាងខ្លាំងអស់ជាច្រើនសតវត្សមក ក៏នៅតែមានពួកយូដាខ្លួនឯង យល់ឃើញថា ពួកគេមិនត្រូវបានគេស្អប់ខ្លាំងនោះទេ ។ ដូច្នេះហើយបានជាពួកគេ បានស្នាក់នៅយ៉ាងស្កប់ចិត្ត នៅតាមកន្លែងផ្សេងៗក្នុងពិភពលោក។ ជាលទ្ធផល ពួកគេមានទំនោរងាកទៅរកការបាត់បង់ ផ្នត់គំនិតនៃការជាប់ពាក់ព័ន្ធរបស់ពួកគេកាលពីសម័យបុរាណ ទៅនឹងទឹកដីសន្យា។

ទោះជាយ៉ាងណា ក៏នៅតែមានអ្នកដឹកនាំសាសន៍យូដាម្នាក់ដែលរស់នៅទ្វីបអឺរ៉ុប លោកបណ្ឌិត ធាឌ័រ ហឺស្សល (Theodore Herzl) មិនអាចនៅស្ងៀមបាននោះទេ នៅពេលដែលលោកបានឃើញការកើនឡើងនៃការបៀតបៀននៅក្នុងប្រទេស រ៉ូស៊ី នៅជិតចុងបញ្ចប់សតវត្សទីដប់ប្រាំបួន។ ដោយជឿថារឿងរ៉ាវនឹងអាចឈានទៅរកភាពធ្ងន់ធ្ងរជាងនេះទៅទៀតសម្រាប់ប្រជាជនរបស់លោក លោកបានព្យាយាមបាននាំឲ្យពួកគេចាប់អារម្មណ៍ទៅលើផ្នត់គំនិតមួយអំពីការបង្កើតទឹកដីកំណើតរបស់ពួកគេមួយនៅប្រទេសប៉ាគីស្ថាន។ ការខិតខំព្យាយាមរបស់លោកបង្កើតបានទៅជា "ចលនាស៊ីយ៉ូន"សម័យថ្មី ប៉ុន្តែក្រោយមកត្រូវបានបរាជ័យ។ ជាឧទាហរណ៍ពួកយូដា នៅប្រទេសអាល្លឺម៉ង់ បាននិយាយថា "ពួកយើងមិនបានដឹងអ្វីអំពីស៊ីយ៉ូននោះទេ ។ ប្រទេសអាល្លឺម៉ង់គឺជាប្រទេសភីលីស្ទីនសម្រាប់យើង ហើយ ទីក្រុងមុយនិចគឺជាក្រុងយេរូសាឡឹមសម្រាប់យើង។

ស្របពេលដែលពិភពលោកបានវិវត្តន៍ឈានទៅរកភ្លើងសង្គ្រាមនៅអឺរ៉ុប ពួកយូដាក៏បានឃើញថាជីវិតរបស់គេកាន់តែពិបាកខ្លាំងទៅៗ។ បន្ទាប់មកនៅក្នុងសង្គ្រាមលោកលើកទី១ ចលនាស៊ីយ៉ូន បានដាក់សំពាធទៅលើរដ្ឋាភិបាលអង់គ្លេសជាខ្លាំង ដែលនាំឲ្យមានចេញ*សេចក្តីប្រកាសបាលហ្វ័រ* (Balfour Declaration)។ សេចក្តីប្រកាសនេះ ស្នើឲ្យប្រទេសអង់គ្លេសគាំទ្រការបង្កើតទឹកដីកំណើតផ្ទាល់ខ្លួនមួយសម្រាប់ពួកយូដា នៅប្រទេសភីលីស្ទីន ។ នៅពេលដែលពួកអង់គ្លេសបានចូលទៅគ្រប់គ្រង់លើទឹកដីដ៏វិសុទ្ធ ក្រោយសង្គ្រាមចប់ ពួកយូដាក៏ត្រូវបានលើកទឹកចិត្តឲ្យភៀសខ្លួនទៅប្រទេសភីលីស្ទីន។ មានពួកយូដាជាច្រើននាក់ បានត្រឡប់មកនៅរួមគ្នាជាមួយនឹងពួកអារ៉ាប់ ដែលបានរស់នៅលើទឹកដីនោះរាប់សិបសតវត្សមកហើយ។

មិនយូរប៉ុន្មាន នៅសង្គ្រាមលោកលើកទី២ បាននាំឲ្យមានការគម្រាមកំហែង និង ការបៀតបៀនដល់ពួកយូដាយ៉ាងប្រាកដ។ នៅអឺរ៉ុប ការនេះមានភាពធ្ងន់ធ្ងរខ្លាំងណាស់ ដែលមានពួកយូដាជាច្រើនបានគិតថា ក្តីសង្ឃឹមតែមួយគត់ដើម្បីឲ្យពួកគេរស់រានមានជីវិតបាន គឺមានតែការចាកចេញពីអឺរ៉ុប ហើយវិលត្រឡប់ទៅទឹកដីពីបុរាណរបស់ពួកគេវិញ។ ក្រោយចប់សង្គ្រាមលោកលើកទី២ ពួកយូដាជាច្រើនអ្នកបានចាកចេញពីផ្ទះបណ្តោះអាសន្នរបស់ពួកគេ វិលទៅភីលីស្ទីនវិញ។ ដល់ពាក់កណ្តាលខែ ឧសភា ឆ្នាំ ១៩៤៨ ការវិលត្រឡប់មកវិញរបស់ពួកយូដាក៏បាន ដាក់ប្រកាសជាថ្ងៃកំណើតនៃរដ្ឋអ៊ីស្រាអែល បច្ចុប្បន្ននេះ។ មិនយូរក្រោយមក បទទំនាយនៅក្នុងគម្ពីរអេម៉ុស ៩:១៤-១៥ ក៏ចាប់ផ្តើមបានសម្រេចកើតមានពិតប្រាកដមែន។

> ពេលនោះ យើងនឹងនាំអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់យើងដែលជាប់ជាឈ្លើយ អោយត្រឡប់មកវិញ។ ពួកគេនឹងសង់ក្រុងទាំងប៉ុន្មានដែលខូចខាត ដើម្បីស្នាក់នៅ។ ពួកគេនឹងដាំទំពាំងបាយជូរ ហើយផឹកស្រាពីចំការទំពាំងបាយជូរនោះ។ ពួកគេនឹងធ្វើចំការ ហើយបរិភោគផលផ្លែពីចំការនោះដែរ។ យើងនឹងអោយពួកគេរស់នៅយ៉ាងស្ថិតស្ថេរលើទឹកដីរបស់ខ្លួន គ្មាននរណាអាចបណ្តេញពួកគេចេញពីស្រុកដែលយើងបានប្រគល់អោយពួកគេនេះទៀតឡើយ» - នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នក។

ទឹកដីនោះហាក់បីដូចជា ឥតបានការ អស់រយៈពេលជិត ២០០០ឆ្នាំមកហើយ។ ព្រះជាម្ចាស់បានមានព្រះបន្ទូលថា ទឹកដីនេះនឹងត្រូវរីកស្គុសស្គាយឡើងដូចជាផ្កា (គម្ពីរអេសាយ ៣៥:១-២)។ បទទំនាយរបស់លោកហោរាអេសាយ ក៏ត្រូវបានសម្រេច។ កន្លែងដែលធ្លាប់តែត្រូវបោះបង់ចោល ត្រូវបានយកត្រឡប់មកវិញ ហើយទីក្រុងដែលបានបែកបាក់ ក៏មានមនុស្សឡើងវិញ មានការកសាងជាថ្មី ហើយពង្រឹងឲ្យមាំម្តងទៀត (គម្ពីរអេសេគាល ៣៦:៣៣-៣៦ សូមមើលនៅក្នុងគម្ពីរអេសាយ ៦១:៤ផងដែរ) ។ មានប្រវត្តិវិទូម្នាក់បានសំគាល់ឃើញថា សង្គ្រាមលោកលើកទីមួយគឺជាការរៀបចំ ទឹកដីសន្យាសម្រាប់ពួកយូដា ហើយសង្គ្រាមលោកលើកទី ២ បានរៀបចំពួកយូដាសម្រាប់ទឹកដីរបស់ពួកគេ ហើយសង្គ្រាមដែលនឹងកើតឡើងក្នុងថ្ងៃអនាគត នឹងរៀបចំពួកយូដាសម្រាប់ព្រះជាម្ចាស់របស់ផងគេ។

បើអ្នកណា យកចិត្តទុកដាក់ជាមួយនឹងបញ្ហានៅ តំបន់មជ្ឈិមបូព៌ា គេដឹងថា ជាមួយនឹងការវិលត្រឡប់មកវិញរបស់ពួកយូដា ចូលក្នុងទឹកដីពីបុរាណរបស់ពួកគេ ពួកភីលីស្ទីនជាច្រើនដែលបានរស់នៅទីនោះជាយូរមកហើយ ត្រូវបានគេផ្លាស់ទីកន្លែងរស់នៅ ហើយបានក្លាយជាជនភៀសខ្លួនដែលមានចំនួនច្រើនជាងគេនៅក្នុង ប្រទេសផ្សេងៗទៀតនៅតំបន់មជ្ឈិមបូព៌ានោះ។ ការនេះជាមូលហេតុដែលបណ្តាលឲ្យមានការកើនឡើងនូវភាពតានតឹង និងការប្រេះឆា រវាងពួកយូដា និង ប្រទេសជិតខាងក្នុងតំបន់អារ៉ាប់។ យើងនឹងឃើញនៅពេលក្រោយ ថានេះគឺជាកត្តាដែលនឹងចូលរួមនៅក្នុងការបានបំពេញបទទំនាយដែលទាក់ទងនឹងតំបន់មជ្ឈិមបូព៌ា។

ដោយចងចាំបទទំនាយនេះនៅក្នុងចិត្ត ឥឡូវនេះយើងនឹងបែរទៅរកខ្លឹមសាររបស់គម្ពីរដានីយ៉ែល ៩:២៧ ដែលនិយាយអំពីស្តេចដែលនឹងយាងមក និង ការសម្រេចបាននូវអ្វីដែលព្រះជាម្ចាស់បានដាក់បញ្ញត្តិនៅក្នុងខទី២៤។

## *លំហាត់អនុវត្តន៍*

៩ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខព្រឹត្តិការណ៍ទំនាយដែលបានកើតឡើងរួចហើយ ដូចដែលបានបកស្រាយនៅក្នុងទិដ្ឋភាពខាងលើនេះ ។

ក) ការនិរទេសរបស់ពួកយូដាអស់រយៈពេល៧០ឆ្នាំ គឺដោយសារតែការមិនស្ដាប់បង្គាប់។

ខ) ការជួសជុល និង ការសាងសង់ក្រុងយេរូសាឡឹមឡើងវិញ គឺកើតឡើងក្រោយការជាប់ជាទាសកររយៈពេល៧០ឆ្នាំ។

គ) ការយាងមករបស់លោកដែលគេចាក់ប្រេងអភិសេក។

ឃ) ការមកដល់នៃអ្នកប្រឆាំងនឹងព្រះគ្រិស្ដ។

ង) ការសម្លាប់លោកដែលគេចាក់ប្រេងអភិសេក។

ច) មនុស្សរបស់ស្ដេចដែលកំពុងយាងមក កំទេចទីក្រុងវិសុទ្ធ និង ព្រះវិហារ។

ឆ) ទីបញ្ចប់ជាអធិបតេយ្យភាព របស់សាសន៍យូដា។

ជ) បទទំនាយនៅក្នុងគម្ពីរអេម៉ុស ៩ ដែលប្រាប់ថាប្រទេសអ៊ីស្រាអែល នឹងត្រូវបានស្រោចស្រងឡើងវិញម្ដងទៀត ហើយប្រជារាស្ត្រគេនឹងត្រឡប់មកធ្វើចំការ និង ដាំទំពាំងបាយជូរម្ដងទៀត។

ឈ) សេចក្ដីសន្យារបស់ប្រជារាស្ត្រសាសន៍យូដា និង ស្ដេចដែលកំពុងយាងមក ដែលត្រូវបានបំផ្លាញបានពីរយៈពេលបីឆ្នាំកន្លះ។

## អាទិត្យទីចិតសិបរបស់លោកដានីយ៉ែល

**វត្ថុបំណងទី៣.** *បកស្រាយព្រឹត្តិការណ៍នៅក្នុងសម័យរបស់អ្នកប្រឆាំងនឹងព្រះគ្រិស្ដ និងសមរភូមិនៅឯអើម៉ាគេដូន។*

យើងបានឃើញហើយថា ក្រោយពេលមានការសម្លាប់ព្រះអង្គដែលគេចាក់ប្រេងអភិសេកនោះរួចហើយ ប្រទេសអ៊ីស្រាអែល ក៏ត្រូវបានបញ្ចប់ដែរ។ នៅក្នុងអំឡុងពេលជាមួយគ្នានេះដែរ ក្រុមជំនុំក៏បានកើតឡើង ហើយបានចាប់ផ្ដើមធ្វើបេសកកម្មដែលព្រះជាម្ចាស់បានប្រទានមក។លោកសាវ័កប៉ូលបានធ្វើការប្រកាសនៅក្នុងគម្ពីររ៉ូមជំពូក៩ ដល់១១ថា ព្រះជាម្ចាស់មិនបានលះបង់ចេញ**ពី**សាសន៍អ៊ីស្រាអែលទាំងស្រុងនោះទេ ។ ប៉ុន្ដែនៅក្នុងពេលជាមួយគ្នានោះដែរ ទ្រង់បានចាត់ឲ្យក្រុមជំនុំ ធ្វើជាឧបករណ៍ផ្សព្វផ្សាយដំណឹងល្អរបស់ទ្រង់ នៅពេលដែលអ្នកជឿចែកចាយដំណឹងល្អជាមួយមនុស្សទាំងអស់នៅក្នុងពិភពលោក។ នៅក្នុងចន្លោះពេលរវាងការសម្លាប់ព្រះអង្គដែលគេចាក់ប្រេងអភិសេក និង ការបំពេញ (ការសម្រេចបាន)ផែនការរបស់ព្រះជាម្ចាស់ទៅថ្ងៃអនាគត សម្រាប់ពួកអ៊ីស្រាអែល ក្រុមជំនុំបានបន្តតួនាទីទៅមុខទៀតដដែល។

ភស្តុតាងនៅក្នុងព្រះគម្ពីរបានចង្អុលបង្ហាញទៅកាន់ការពិតដែលថាក្រុមជំនុំគឺកំពុងតែរងចាំព្រះអម្ចាស់ដែលកំពុងយាងមកដើម្បីលើកយកពួកគេទៅ (គម្ពីរ១កូរិនថូស ១៥:៥០-៥២ គម្ពីរ

១ថេស្សាឡូនិក ៤:១៣-១៧)។ ទោះបីជាយ៉ាងណា បើមើលទៅហាក់បីដូចជា ស្តេចមួយអង្គដែលនឹងមកដល់នោះ ត្រូវបានព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការតាមរយៈក្រុមជំនុំ ដើម្បីបង្ខាំង ឬ ឃាត់មិនឲ្យធ្វើតាមផែនការអាក្រក់បាន (គម្ពីរ២ថេស្សាឡូនិក ២:១-១២)។ នៅពេលដែលក្រុមជំនុំត្រូវបានឆក់យកឡើង ឬ ចាប់យកឡើងទៅ អាទទឹងច្បាប់ ក៏នឹងចេញមុខមក។ បន្ទាប់មកព្រះជាម្ចាស់នឹងបង្វែរព្រះទ័យទុកដាក់របស់ទ្រង់ទៅលើពួកអ៊ីស្រាអែលសាជាថ្មីម្តងទៀត ស្របពេលដែលព្រឹត្តិការណ៍នៃអាទិត្យទីចិតសិបរំកិលខិតទៅរកក្តីសម្រេច។

យើងបានសំគាល់ឃើញថាព្រះគម្ពីរដានីយ៉ែល គឺចែងឡើងទាក់ទងនឹងពួកយូដា។ នៅពេលដែលលោកយេរេមាសង្កេតមើលអំឡុងពេលនេះ លោកប្រៀបធៀបការឆ្លងកាត់របស់ពួកអ៊ីស្រាអែលទៅនឹងការឈឺចាប់ដែលម្តាយត្រូវអត់ទ្រាំនៅពេលគាត់ឆ្លងទន្លេ (គម្ពីរយេរេមា ៣០:១-១១)។ បើនិយាយអំពីការរងទុក្ខ គ្មានពេលណាមួយនៅក្នុងប្រវត្តិសាស្ត្រអាចប្រៀបជាមួយនឹងអំឡុងពេលមួយនេះឡើយ ពេលនេះគឺជា "ថ្ងៃដែលកូនចៅរបស់យ៉ាកុបត្រូវឈឺចុកចាប់យ៉ាងខ្លាំង"។ នេះមានន័យថា "ថ្ងៃដែលសាសន៍អ៊ីស្រាអែលត្រូវឈឺចាប់" ។ តើបញ្ហាទាំងអស់នេះនឹងចូលមកដោយរបៀបណា?

## អ្នកប្រឆាំងនឹងព្រះគ្រិស្ត

បើអ្នកនៅចាំគម្ពីរដានីយ៉ែល ៩:២៦ ដែលថ្លែងអំពីស្តេចមួយដែលនឹងមកដល់ ហើយនៅក្នុងខ២៧ បានបង្ហាញអំពីសកម្មភាពរបស់ស្តេចនោះ។ យើងឃើញថា ស្តេចនោះនឹងធ្វើការសន្យាជាមួយនឹងមនុស្សជាច្រើន រយៈពេល "មួយអាទិត្យ" (៧ឆ្នាំ) ។ ជាក់ស្តែង ភាពតានតឹងនៅ មជ្ឈិមបូព៌ា រវាងសាសន៍យូដា និង ប្រទេសសាសន៍អារ៉ាប់ជិតខាងរបស់ពួកគេនឹងបន្តរហូតដល់ពេលដែលគ្រាមានវិបត្តិធំបំផុតចាប់ផ្តើមកើតឡើង ហើយការនេះនឹងច្បាស់ជាគំរាបកំហែងដល់សន្តិភាពពិភពលោក។ នៅត្រង់ចំណុចនេះ ស្តេចមួយដែលនឹងយាងមកដល់ (អ្នកប្រឆាំងនឹងព្រះគ្រិស្ត) នឹងឈានទៅរកការបង្កើតឲ្យបាននូវសុខសន្តិភាព។ ភាពជោគជ័យខាងឯការទូតរបស់ស្តេចនោះ នឹងត្រូវបានគេចាត់ទុកជាជ័យជម្នះដ៏ធំមួយ ហើយមនុស្សម្នានៅក្នុងពិភពលោកនឹងប្រកាសថាស្តេចនោះគឺជាស្តេចដែលគ្មានអ្នកណាប្រៀបស្មើរ (គម្ពីរវិវរណៈ ១៣:៤)។

អ៊ីស្រាអែលនឹងរំពឹងឲ្យអ្នកបង្កើតសន្តិភាពរូបនេះ រក្សាសន្តិភាពសម្រាប់ពួកគេ។ ដោយគ្មានកង្វល់ក្នុងការត្រៀមវិស័យយោធាឲ្យមានភាពខ្លាំងក្លា ប្រជាជនសាសន៍យូដានឹងអាចបង្វែរលុយ និង កម្លាំងរបស់ពួកគេទៅលើគោលដៅដែលបានសន្តិភាព ដូចជាៈ ការអភិវឌ្ឍទឹកដី ការលើកស្ទួយកម្រិតនៃការរស់នៅរបស់ពួកគេ និង ការស្វែងរកលំនៅនិងការងារសម្រាប់មនុស្សដែលគ្មានទីលំនៅជាច្រើននាក់។ ការធ្វើការសន្យាសន្តិភាពនេះ នឹងធ្វើឲ្យអ្នកផ្តល់សន្តិភាពត្រូវបានគេចាត់ទុកថាៈ "អាទទឹងច្បាប់,មនុស្សទទឹងច្បាប់" (គម្ពីរ២ថេស្សាឡូនិក ២:៣)។

នៅក្នុងមួយរយៈពេល អ្វីនឹងដំណើរការបានយ៉ាងល្អនៅក្នុងតំបន់ទាំងមូល ប៉ុន្តែបានពាក់កណ្តាលការសន្យានេះ ស្តេចមួយនោះនឹងក្បត់ពាក្យសន្យារបស់គេ (គម្ពីរដានីយ៉ែល ៩:២៧)។ អត្ថបទព្រះគម្ពីរបានថ្លែងថា ស្តេចនោះនឹងបញ្ឈប់លែងឲ្យមានសាសនា និង សិទ្ធិជាប្រជាជននៅ

អ៊ីស្រាអែល។ នៅក្នុងកន្លែងថ្វាយបង្គំតាមក្រឹត្យវិន័យរបស់ពួកគេ ក៏ត្រូវបានស្តេចនោះធ្វើ*ការប្រមាថដែលគួរឲ្យស្អប់ខ្ពើមយ៉ាងខ្លាំង* (ការបំពានដែលគួរឲ្យស្អប់ និង អាក្រក់ជាទីបំផុតនៅក្នុងកន្លែងសក្ការៈសម្រាប់ព្រះជាម្ចាស់) នៅក្នុងព្រះវិហារ។ ដោយស្តេចនេះនឹងតាំងខ្លួនឯងជាព្រះ (ប្រកាសថាខ្លួនជាព្រះជាម្ចាស់) និង ទាមទារឲ្យគេថ្វាយបង្គំខ្លួន (សូមមើលនៅក្នុងគម្ពីរ២ថេស្សាឡូនិក ២:៤,៨-១១ គម្ពីរវិវរណៈ ១៣:១៣-១៥) យើងឃើញថាស្តេចនេះនឹងតាំងរូបភាពរបស់ខ្លួននៅក្នុងព្រះវិហារ ហើយតម្រូវឲ្យពួកយូដាថ្វាយបង្គំ បើគេមិនចង់ស្លាប់។ ស្តេចនេះនឹងទទួលជំនួយពីភ្នាក់ងារពិសេសដែលត្រូវបានគេហៅថា "មន្ត្រីខាងឃោសនា"។ ព្យាការីក្លែងក្លាយនេះ នឹងសម្តែងការអស្ចារ្យ និងមានពេញដោយអំណាច ការអាក្រក់ក៏នឹងជះឥទ្ធិពលលើមនុស្សដែរ (គម្ពីរវិវរណៈ ១៣:១៣; ១៦:១៣)។

ព្រះយេស៊ូព្រះបន្ទូលអំពី ទង្វើនៃការប្រមាថដ៏ធំនេះ ដោយហៅវាថា " សេចក្តីស្អប់ខ្ពើមដែលបង្ខូចបំផ្លាញ" (ពាក្យក្នុងគម្ពីរពគប) ។ ទ្រង់បានធ្វើការដាស់តឿនថា៖ "កាលណាអ្នករាល់គ្នាឃើញសេចក្តីដែលហោរាដានីយ៉ែលបានទាយទុក គឺជាសេចក្តីស្អប់ខ្ពើមដែលបង្ខូចបំផ្លាញ វាឈរនៅក្នុងទីបរិសុទ្ធ ....នោះត្រូវឲ្យពួកអ្នកដែលនៅស្រុកយូដារត់ចេញទៅឯភ្នំ (គម្ពីរម៉ាថាយ ២៤:១៥-១៦ *ពគប*) ។ តាមរយៈភាសានិមិត្តសញ្ញាដែលពេញដោយឫទ្ធានុភាព យើងបានដឹងអំពីសេចក្តីវេទនាដែលពួកយូដានឹងត្រូវឆ្លងកាត់ នៅពេលដែលប្រព័ន្ធសង្គមដ៏អាក្រក់នៅគ្រាចុងក្រោយព្យាយាមបំផ្លាញប្រទេសអ៊ីស្រាអែល (សូមមើលនៅក្នុងគម្ពីរវិវរណៈ ១២:១៣-១៧ គម្ពីរដានីយ៉ែល ១២:១,៦-៧)។

នៅក្នុងពេលជាមួយគ្នានេះដែរ នឹងមានភាពវឹកវរ និង ការលំបាកជាច្រើនសម្រាប់អ្នកដែលមិនមែនជាសាសន៍យូដា ដ្បិតនឹងមានការវិនិច្ឆ័យបីដងបន្តបន្ទាប់គ្នា ធ្លាក់មកលើមនុស្សដែលរស់នៅលើផែនដី។ គម្ពីរវិវរណៈជំពូក ៦,៨,៩,១៥ និង ១៦ បានរៀបរាប់ អំពីការកើនឡើងនៃព្រះពិរោធរបស់ព្រះជាម្ចាស់ដែលទ្រង់ចុះមកគ្របលើអាណាចក្ររបស់ "ស្តេចមួយអង្គដែលនឹងមកដល់" ស្របពេលដែលវេលាចេះតែរំកិលទៅមុខ។

នៅពេលដែលស្តេចមួយដែលអាក្រក់នោះ ស្វែងរកការបំពេញកម្លាំងសម្រាប់ខ្លួនឯង ស្តេចនោះនឹងប្រើប្រាស់ប្រព័ន្ធនៅក្នុងពិភពលោកនេះ ដើម្បីគ្រប់គ្រងលើហិរញ្ញវត្ថុ និង ឥតទានទាំងអស់។ តាមរយៈមធ្យោបាយនេះ ស្តេចនោះនឹងអាចបង្ខិតបង្ខំមនុស្សឲ្យទទួលការដឹកនាំរបស់ខ្លួន ដោយព្រោះតែគ្មាននរណាម្នាក់អាចធ្វើជំនួញអ្វីបាននោះទេ ដរាបណាគេបានទទួលសញ្ញាសំគាល់ដែលស្តេចអង្គនេះបានកំណត់ឲ្យ (គម្ពីរវិវរណៈ ១៣:១៦-១៧)។ ស្របពេលដែលស្តេចអង្គនេះ ខំប្រឹងប្រែងកសាងរដ្ឋាភិបាលនៃពិភពលោករួមមួយ នោះគេនឹងជួបប្រទះការជំទាស់ប្រឆាំង។ ដូច្នេះ នឹងមានសង្គ្រាមមួយកើតឡើងនៅពាក់កណ្តាលរយៈពេលប្រាំពីរឆ្នាំនៃការគ្រប់គ្រងរបស់ស្តេចនេះ។

ដោយមានការបណ្តាលចិត្តដោយព្រះវិញ្ញាណឲ្យធ្វើការទស្សន៍ទាយ លោកអេសេគាលបានបង្ហាញថា សហព័ន្ធនៃប្រទេសភាគខាងជើង នឹងមកគ្រប់ដណ្តប់លើប្រទេសអ៊ីស្រាអែល ដែលកំពុងតែរីករាយជាមួយនឹងសុខសុវត្ថិភាពដែលអាទទឹងច្បាប់បានផ្តល់ឲ្យ។ កងទ័ពជាច្រើនកោះករនៅក្នុងសង្គ្រាមនេះគេរំពឹងថានឹងអាចកំទេចអ៊ីស្រាអែលបាន ប៉ុន្តែពួកគេមិនបានគិតដល់ព្រះហឫទ័យទុកដាក់របស់ព្រះជាម្ចាស់សម្រាប់ប្រជារាស្ត្ររបស់ទ្រង់នោះទេ ។ នៅពេលមានការវាយលុកកើតមានឡើង ព្រះជាម្ចាស់បានការពារប្រជារាស្ត្ររបស់ទ្រង់ ហើយស្ទើរតែបានកំទេចកងកម្លាំងឈ្លានពានទាំងអស់តែម្តង

(គម្ពីរអេសេគាល ៣៨-៣៩)។ កងកម្លាំងផ្សេងទៀតក៏មានភាពចលាចលខ្លួនឯង ហើយអាទទឹងច្បាប់ក៏បានបង្ខំចិត្តដើម្បីប្រកាសការពារនូវសិទ្ធិគ្រប់គ្រងរបស់វា។

## អើម៉ាគេដូន

ក៏ដូចគ្នានេះដែរ លោកដានីយ៉ែល បានកត់សំគាល់ឲ្យឃើញថាការទាស់ប្រឆាំង នឹងលេចឡើងនៅកន្លែងផ្សេងៗ។ ការនេះធ្វើឲ្យអាទទឹងច្បាប់ នៅតែបន្តដំណើរទៅបំផ្លាញអ្នកទាស់ប្រឆាំងនឹងវា (គម្ពីរដានីយ៉ែល ១១:៤០-៤៥)។ ជាក់ស្តែង រដ្ឋាភិបាលពិភពលោករួមមួយរបស់គេ នឹងត្រូវបានបំផ្លាញដោយការបែកបាក់ (ការមិនយល់ស្របគ្នា) នៅពេលដែលគ្រាចុងក្រោយខិតចូលមកដល់។ នៅគ្រាដែលពេលវេលាចុងក្រោយជិតចូលមកដល់ ព្រះជាម្ចាស់នឹងត្រាស់ហៅកងទ័ពទាំងអស់ក្នុងពិភពមករួមគ្នា ហើយធ្វើចំបាំងចុងក្រោយដ៏ធំអស្ចារ្យមួយនៅក្នុងប្រវត្តិសាស្ត្រ នៅកន្លែងមួយដែលគេហៅថា *អើម៉ាគេដូន* (គម្ពីរវិវរណៈ ១៦:១៦)។

យ៉ាងណាមិញ នៅអើម៉ាគេដូន បញ្ហានឹងមិនត្រូវបានសម្រេចដោយអាវុធទំនើបៗរបស់មនុស្ស ចំនួនរបស់កងទ័ព ឬ ការប្តេជ្ញាចិត្តរបស់អ្នកចំបាំងឡើយ។ *ព្រះជាម្ចាស់នឹង ធ្វើឲ្យកងទ័ពភ្ញាក់ផ្អើលនៅពេលដែលទ្រង់ធ្វើការវាយប្រហារ។* លទ្ធផលគឺនឹងគួរឲ្យខ្លាច ដែលមិនអាចបកស្រាយបាននោះទេ (សូមមើលនៅក្នុងគម្ពីរវិវរណៈ១៩:១៩-២១)។

មនុស្សក្រអឺតក្រទម នឹងមិនត្រឹមតែប្រមាថព្រះជាម្ចាស់នៅក្នុងការប្រយុទ្ធប៉ុណ្ណោះទេ ប៉ុន្តែមកដល់ចំណុចត្រង់នេះ ពួកគេក៏ស្ទើរតែនឹងបំផ្លាញអ៊ីស្រាអែលទៅហើយ។ ទោះជាយ៉ាងណា នៅពេលដែលព្រះអម្ចាស់យេស៊ូនៃយើងទ្រង់យាងមកដល់ នោះនឹងមានរឿងជាច្រើនកើតឡើង។ ស្របពេលដែល អ៊ីស្រាអែលទទួលរងការបំភ្លិចបំផ្លាញពីសំណាក់ពួកខ្មាំងសត្រូវ ពួកគេស្រាប់តែទទួលបានការផ្លាស់ប្តូរ ដួងចិត្តរបស់ពួកគេ (សូមមើលនៅក្នុងគម្ពីរសាការី ១៤:៤-៥,១២-១៥)។ ព្រះអង្គ (ព្រះយេស៊ូ) ដែលនឹងដឹកនាំនៅក្នុងសង្គ្រាម មិនមែនជានរណាផ្សេងទៀតទេ គឺព្រះអង្គដែលពួកឪពុករបស់ពួកគេបានបដិសេធនោះឯង។ ឥឡូវព្រះអង្គដែលត្រូវបានគេចាក់ទម្លុះនេះ ទ្រង់បាននាំមកនូវការប្រោសលោះប្រកបដោយចេស្តា។ ជាមួយនឹងការបង្ហាញព្រះកាយរបស់ទ្រង់ ប្រជារាស្ត្រយូដាដែលបានរស់រានមានជីវិត ក៏ត្រូវបានបំបាក់ដោយវិញ្ញាណសោកសង្រេង (គម្ពីរសាការី ១២:១០- ១៣:១) ហើយពួកគេទទួលយកព្រះអង្គដែលបានយាងមកនៅក្នុងព្រះនាមព្រះអម្ចាស់។ ឥឡូវនេះ ចំណុចសំខាន់ជាច្រើនផ្សេងទៀតនៃផែនការរបស់ព្រះជាម្ចាស់ដែលកត់ត្រានៅក្នុងគម្ពីរដានីយ៉ែល ៩:២៤ ត្រូវបានលើកយកមកបង្ហាញ ស្របពេលដែលយើងនឹងឃើញអំពីការនេះនៅក្នុងទិដ្ឋភាពបន្ទាប់ទៀតនេះ។

## *លំហាត់អនុវត្តន៍*

១០ តើការលើកឡើងមួយណា ក្នុងចំណោមខាងក្រោមនេះ ជាចម្លើយត្រឹមត្រូវ ទាក់ទងនឹងព្រឹត្តិការណ៍នៅក្នុងសម័យរបស់អ្នកប្រឆាំងនឹងព្រះគ្រិស្ត និង ក្នុងសម័យសង្គ្រាមនៃអើម៉ាគេដូន?

ក) ឈ្មោះផ្សេងៗទៀតរបស់អ្នកប្រឆាំងនឹងព្រះគ្រិស្ត គឺ *ស្តេចមួយដែលនឹងមកដល់* និង *មនុស្សទទឹងច្បាប់។*

ខ) លោកដែលគេចាក់ប្រេងអភិសេកនោះ គឺសំដៅទៅលើព្រះយេស៊ូគ្រិស្ត។

គ) នៅពេលដែលក្រុមជំនុំបានកើតឡើង ព្រះជាម្ចាស់បានលែងទទួលស្គាល់ប្រជាជាតិយូដាទាំងស្រុងរួចទៅហើយ។

ឃ) មុនពេលស្តេចមួយដែលនឹងមកដល់ លេចឡើងមក ក្រុមជំនុំនឹងត្រូវបាន "ចាប់យកទៅ" ឬ ត្រូវបានឆក់យកទៅ។

ង) អ៊ីស្រាអែលនឹងត្រូវបានលើកលែងពីការបានវិនិច្ឆ័យទោស និង ទុក្ខវេទនានៅគ្រាចុងក្រោយ។

ច) អ្នកប្រឆាំងនឹងព្រះគ្រិស្តនឹងសម្រេចបានការសន្យាសន្តិភាពរយៈពេលប្រាំពីរឆ្នាំ ជាមួយនឹងអ៊ីស្រាអែល ដែលនេះនឹងក្លាយជាអំឡុងពេលមួយដែលមានសន្តិភាពអស្ចារ្យ និង ចម្រុងចម្រើនពាសពេញពិភពលោក។

ឆ) បទគម្ពីរបញ្ជាក់ថា អ្នកប្រឆាំងនឹងព្រះគ្រិស្ត នឹងបំភ្លេចការសន្យារបស់គេជាមួយនឹងអ៊ីស្រាអែល ព្រមទាំងបំពានព្រះវិហារដ៏វិសុទ្ធថែមទៀតផង។

ជ) អ្នកប្រឆាំងនឹងព្រះគ្រិស្តនឹង បានគ្រប់គ្រងលើពិភពលោកទាំងមូល ហើយបង្ខំឲ្យមនុស្សគ្រប់គ្នាទទួលយកសញ្ញារបស់ខ្លួន បើសិនជាចង់ធ្វើជំនួញអ្វីមួយ។

ឈ) អ្នកដែលធ្វើការវាយប្រហារដំបូងគេ នៅក្នុងសមរភូមិនៃអើម៉ាគេដូន គឺជាពួកទាហានដែលកំពុងប្រមូលផ្តុំគ្នា រួមជាមួយនឹងអាវុធដ៏ខ្លាំងពូកែរបស់គេ។

ញ) ព្រះយេស៊ូគ្រិស្តនឹងយាងមកឯប្រជាជាតិយូដា ក្នុងនាមជាព្រះអម្ចាស់របស់ពួកគេក្នុងពេលណាមួយ។

# គ. ការបើកសម្តែងរបស់ព្រះយេស៊ូគ្រិស្ត

**វត្ថុបំណងទី ៤.** *បកស្រាយថាតើមានលក្ខខ័ណ្ឌអ្វីខ្លះ ដែលនឹងនាំឲ្យមានការបើកសម្តែងរបស់ព្រះគ្រិស្ត និង រៀបរាប់អំពីលទ្ធផលចុងក្រោយរបស់អ្នកដឹកនាំនៃគូបដិបក្សទាំងពីរ។*

## លក្ខខ័ណ្ឌ

ស្របពេលដែលព្រឹត្តិការណ៍នៃគ្រាមហាវេទនា កំពុងដែលកើតមានឡើង អ្នកជឿគឺកំពុងតែនៅជាមួយនឹងព្រះអម្ចាស់របស់ពួកគេ។ ស្របពេលដែលចំណងនៃអំពើអាក្រក់ ផុសផុលឡើង ហើយភាពមានបាបរបស់មនុស្សលោកកាន់តែឈានទៅដល់កំពូលដ៏ខ្ពស់បំផុត ទិដ្ឋភាពទីពីរនៃការយាងមករបស់ព្រះអម្ចាស់ក៏នឹងកើតឡើង នោះគឺការបើកសម្តែងរបស់ទ្រង់ទៅកាន់មនុស្សដែលនៅក្នុងលោកីយ៍ និង ទៅ

កាន់ទាហារដែលបានប្រមូលផ្តុំនៅលើផែនដី (គម្ពីរវិវរណៈ ១:៧; ១៩:១១-២១)។ នៅក្នុងពេលនេះ អ្នកជឿក៏មកជាមួយនឹងព្រះអម្ចាស់ នៅពេលដែលទ្រង់ត្រឡប់មកលើផែនដី (គម្ពីរកូឡុស ៣:៤)។

បន្ទាប់មកទៀត នៅក្នុងពេលនេះ លក្ខខ័ណ្ឌពីរយ៉ាងនឹងឈានទៅរកកម្រិតមួយដែលគេមិនអាចទទួលយកបាន។ លក្ខខ័ណ្ឌទីមួយគឺ *ការមិនគោរពកោតខ្លាចព្រះជាម្ចាស់ និង ភាពអាត្មានិយមរបស់មនុស្សលោក។* នោះហើយជាហេតុដែលមានទេវតាពីររូប ស្រែកឡើងថា ផលផ្លែបានទុំអស់ហើយ (គម្ពីរវិវរណៈ ១៤:១៥)។ ពេលវេលានៃការប្រមូលផលយ៉ាងពិនិត្យពិច័យ បានមកដល់ហើយ។ ព្រះជាម្ចាស់ដែលបានប្រទានឲ្យមនុស្សនូវសេរីភាព ក្នុងការសម្រេចចិត្ត ពេលនេះនឹងមិនអនុញ្ញាតឲ្យពួកគេធ្វើតាមបំណងចិត្តដ៏វៀចវេររបស់ពួកគេទៀតទេ។ អស់អ្នកដែលសង្ស័យ និង អ្នកមិនជឿ ដែលទាស់នឹងគ្រប់ផ្នត់គំនិតអំពីព្រះជាម្ចាស់ដ៏វិសុទ្ធនឹងត្រូវបានបំបិទឲ្យស្ងាត់។ បញ្ហាអំពើបាប ត្រូវបានដោះស្រាយឲ្យរួចស្រេចជារៀងរហូត។ ជាការឆ្លើយតបទៅនឹងអ្វីដែលទេវតាទាំងពីរនោះ បានប្រកាសឡើង ទេវតាផ្សេងទៀតនឹងថ្លែងឡើងតាមបែបប្រៀបធៀបថា បោះកាំបិតរបស់លោកមកលើផែនដី ផ្លែទំពាំងបាយជូរនៅលើផែនដីក៏កាត់រួចរាល់ជាស្រេច ហើយលោកបោះផ្លែទំពាំងបាយជូរទៅក្នុងធុងបញ្ជាន់ផ្លែ ជាធុងនៃព្រះពិរោធដ៏ខ្លាំងរបស់ព្រះជាម្ចាស់ (គម្ពីរវិវរណៈ ១៤:១៩)។

លក្ខខ័ណ្ឌទីពីរ ដែលព្រះជាម្ចាស់នឹងមិនបានទ្រាំតទៅទៀតបាននោះគឺ *ការបៀតបៀនទៅលើអ៊ីស្រាអែល។* ដូចដែលយើងបានឃើញហើយថា មនុស្សទទឹងច្បាប់នឹងធានាឲ្យបានថា ការសម្លាប់ផ្តាច់ពូជ (ការបំផ្លាញទាំងស្រុង) នៃបងប្អូនរបស់ព្រះអម្ចាស់ ក្លាយទៅជាគោលដៅដំបូងរបស់គេ ។ ទោះជាយ៉ាងណា ព្រះជាម្ចាស់នឹងមិនបាននៅស្ងៀមរហូតដែរ នៅពេលដែលបំណងដ៏អាក្រក់នេះចាប់ផ្តើមជាសកម្មភាពឡើង។ ការលូកព្រះហស្តរបស់ទ្រង់ក៏នឹងមកដល់ ដែលនឹងជួយឲ្យការយាងមករបស់ទ្រង់នៅលើផែនដីនេះកើតឡើងបាន។

## *លំហាត់អនុវត្តន៍*

១១ (ចូរជ្រើសរើសចម្លើយមួយ)។ ភាសាប្រៀបធៀបនៅក្នុងគម្ពីរវិវរណៈ ១៤:១៩ មានន័យថាពេលវេលានឹងមកដល់ ពេលណាដែលព្រះជាម្ចាស់នឹង

ក) បំផ្លាញជីវិតរុក្ខជាតិទាំងអស់នៅលើផែនដី។

ខ) នាំមកនូវការវិនិច្ឆ័យចុងក្រោយ ដល់មនុស្សមានបាបទាំងឡាយណាដែលបដិសេធមិនទទួលយកទ្រង់។

គ) ឆក់យកក្រុមជំនុំឡើងទៅ។

ឃ) ធ្វើឲ្យមនុស្សអាក្រក់បំផ្លាញខ្លួនឯង។

# ព្រឹត្តិការណ៍

នៅក្នុងការយាងមកដំបូងរបស់ទ្រង់ ព្រះយេស៊ូបានយាងមកជាបាវបម្រើដែលរងទុក្ខ។ ទ្រង់បានយាងមកក្នុងភូមិដ៏តូចមួយ មិនសូវមានអ្នកណាស្គាល់ ដោយគ្មានការប្រារព្ធពិធី ឬការរៀបចំទទួលពិសេសណាមួយនោះទេ។ មានតែអ្នកគង្វាលពីរបីនាក់ប៉ុណ្ណោះ ដើម្បីថ្វាយសិរីរុងរឿងដែលបានលេចឡើងនៅជ្រលងភ្នំក្នុងស្រុកយូដា នៅពេលដែលពួកទេវតានៃស្ថានសួគ៌ាស្វាគមន៍ការប្រសូតរបស់ទ្រង់ (គម្ពីរលូកា ២:៨-១៥)។ ទោះជាយ៉ាងណា នៅក្នុងការយាងត្រឡប់មកជាលើកទីពីររបស់ទ្រង់ ទ្រង់នឹងយាងមកនៅក្នុងស្រុកដដែលនោះ ជាមួយនឹងសិរីរុងរឿង និង កិត្តិយសដ៏អស្ចារ្យ។ នៅលើកនេះ ទ្រង់នឹងមិនអង្វរមនុស្សទៀតនោះទេ។ ទ្រង់នឹងយាងមកដើម្បីកំទេច ដើម្បីយកជ័យជម្នះ និង ដើម្បីកាន់កាប់សិទ្ធិអំណាចរបស់ទ្រង់ដោយបង្ខំតែម្តង។

មនុស្សម្នានឹងបានឃើញ កងទ័ពនៃស្ថានបរមសុខ នៅពេលដែលពួកគេអមដំណើរព្រះយេស៊ូ ដែលជាអ្នកដឹកនាំពួកគេ។ ពួកគេនឹងរួមចំណែកនៅក្នុងការ តតាំង (មុខទល់នឹងមុខ) រវាងព្រះអម្ចាស់នៃយើងជាមួយនឹងកងពលរបស់មនុស្សទទឹងច្បាប់។ ចូរឲ្យយើងបានកត់សំគាល់យ៉ាងខ្លីនៅត្រង់ អ្វីដែលនឹងសម្រេចបាន នៅក្នុងការបើកសម្តែងរបស់ព្រះអម្ចាស់នៃយើង។

១. គោលដៅភ្លាមៗ នឹងជាការបញ្ចប់សង្គ្រាមរបស់ពួកបះបោរ ដែលបានផ្ទុះឡើងក្នុងទ្រង់ទ្រាយធំទូទាំងសាកលលោក។ (គម្ពីរវិវរណៈ ១៦:១២-២១; ១៩:១១-២១)។

២. ព្រះអម្ចាស់នៃយើង នឹងបើកសម្តែងអង្គទ្រង់ក្នុងនាមជាស្តេចលើស្តេច និង ព្រះអម្ចាស់លើព្រះអម្ចាស់ ។ សាតាំងដែលបានគ្រប់គ្រងលើនគរទាំងអស់នៅក្នុងពិភពលោក នៅក្នុងពេលបច្ចុប្បន្ននេះ នឹងត្រូវបានដកចេញ ហើយព្រះយេស៊ូដែលជាស្តេចពេញសិទ្ធិ ទ្រង់នឹងឡើងគ្រងតំណែងជាស្តេចរបស់ទ្រង់។

៣. ព្រះយេស៊ូនឹងបង្ករឲ្យអ្នកដឹកនាំនៅក្នុងកងពលរបស់សាតាំង អស់អំណាច នៅពេលដែលទ្រង់យកពួកគេទៅឃុំនៅក្នុងបឹងភ្លើងយ៉ាងឆាប់រហ័សបំផុត។ (គម្ពីរវិវរណៈ ១៩:១៩-២១)។

៤. ពិតណាស់ ដូចដែលយើងបានឃើញហើយថា ការបានសង្គ្រោះអ៊ីស្រាអែលនឹងជាអាទិភាពចម្បងជាងគេ។ ព្រឹត្តិការណ៍នៃការយាងត្រឡប់មកវិញរបស់ព្រះអម្ចាស់នៃយើង នឹងនាំឲ្យពួកយូដាបែរត្រឡប់ទៅរកព្រះជាម្ចាស់ ជាមួយនឹងការលន់តួ និង ទុក្ខសោករបស់គេ។ ការសម្អាតខាងវិញ្ញាណឲ្យបានថ្មីឡើងវិញ នឹងកើតឡើង មិនដូចជាអ្វីដែលធ្លាប់កើតមាននៅក្នុងប្រវត្តិសាស្រ្តឡើយ ៖ មនុស្សដែលខ្វាក់ខាងវិញ្ញាណទាំងអស់នេះ នឹងលះបង់ដួងចិត្តដ៏រឹងទទឹងរបស់ពួកគេ ហើយទទួលយកដួងចិត្តដែលមានសាច់ឈាមជាមួយនឹងឫទ្ធានុភាពរបស់ព្រះវិញ្ញាណ ជួយពួកគេក្នុងការប្រកាន់ខ្ជាប់ច្បាប់វិន័យនៃព្រះអាទិកររបស់ពួកគេ (គម្ពីរអេសេគាល ៣៦:២៦-២៧) ។

៥. ចុងក្រោយ ការយាងមករបស់ព្រះអម្ចាស់នៃយើងដែលប្រកបដោយសិរីរុងរឿង នឹងនាំឲ្យមានការសម្រេចបាននូវនគរនៃភាពសុចរិតជាសាកលមួយ និងជានគរដែលមានអាយុកាលមួយពាន់ឆ្នាំ ឬសហស្សវត្សរ៍ ។ ការបង្ហាញដែលច្បាស់ជាងគេបំផុត អំពីលក្ខខ័ណ្ឌក្នុងការចូលទៅក្នុងនគរមួយនេះ គឺផ្អែកទៅលើបទគម្ពីរដែលមានចែងនៅក្នុងគម្ពីរម៉ាថាយ២៥:៣១-៤៦។ បើយើងមើលទៅ ហាក់

បីដូចជារាល់ការប្រព្រឹត្តិទាំងអម្បាល់ម៉ាន ទាក់ទងនឹងពួកយូដាដែលជាបងប្អូលរបស់ព្រះអម្ចាស់នោះ នឹងក្លាយជាការកំណត់ការចូលទៅក្នុងនគរនេះ (សូមមើលគម្ពីរម៉ាថាយ ២៥:៤០) និង គម្ពីរលោកុប្បត្តិ ១២:១-៣)។ រយៈពេលមួយសហស្សវត្សរ៍ នឹងក្លាយជាប្រធានបទដែលត្រូវពិចារណាបន្តទៀត។

## *លំហាត់អនុវត្តន៍*

១២ តើអ្វីជា លក្ខខ័ណ្ឌពីរយ៉ាងធំជាងគេដែលនឹងនាំឲ្យមានការបើកសម្តែងរបស់ព្រះយេស៊ូគ្រិស្ត នៅក្នុងគ្រានៃការប្រោសលោះ ដែលនឹងត្រឡប់មកលើផែនដីវិញជាមួយទ្រង់?

........................................................................................................................................

១៣ តើអ្វីនឹងជាលទ្ធផលសម្រាប់ស្តេចរបស់កងពលបដិបក្សទាំងពីរ នៅពេលដែលពួកគេបានមកជួបទល់មុខគ្នាក្នុងគ្រាចុងក្រោយ?

........................................................................................................................................

# ឃ. រយៈពេលមួយសហស្សវត្សរ៍

**វត្ថុបំណងទី៥.** *ពិភាក្សាអំពីគោលបំណង និង រៀបរាប់អំពីលក្ខណសម្បត្តិនៃរាជ្យមួយឆ្នាំ។*

## គោលបំណងផ្សេងៗនៃរាជ្យមួយពាន់ឆ្នាំ

ព្រះគម្ពីរបានថ្លែងអំពី គ្រាមួយនៃក្តីសុចរិត និង សន្តិភាព យុត្តិធម៌ និង ភាពសំបូរហូរហៀរ ដែលមានទាក់ទងនឹងការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់នៃយើង (គម្ពីរអេសាយ២:១-៤; ៦៥:២០-២២ គម្ពីរមីកា ៤:១-៥)។ នៅក្នុងគម្ពីរវិវរណៈ ២០:១-៧ ចែងថាអំឡុងពេលនោះ គឺមានរយៈពេល១000ឆ្នាំ។ ទោះជាយ៉ាងណា ព្រះរាជ្យត្រូវបានលើកយកទៅនិយាយនៅក្នុងព្រះគម្ពីរតាមរបៀបជាច្រើន។ នៅក្នុងសេចក្តីអធិស្ឋានរបស់ព្រះអម្ចាស់ គឺមាននិយាយអំពីព្រះរាជ្យដែលនឹងមកដល់ (គម្ពីរម៉ាថាយ ៦:១០) ស្របពេលជាមួយគ្នានោះ ព្រះគម្ពីរលូកា ១៩:១១ ព្រះរាជ្យនេះត្រូវបានហៅថា " ព្រះរាជ្យរបស់ព្រះជាម្ចាស់"។ គម្ពីរវិវរណៈ:១១:១៥ និយាយអំពី "ព្រះរាជ្យរបស់ព្រះអម្ចាស់នៃយើង និង ព្រះគ្រិស្តរបស់ព្រះអង្គ"។ គម្ពីរដានីយ៉ែល ជំពូក៧ ហៅព្រះរាជ្យនេះថា "អំណាចគ្រប់គ្រងរបស់លោកនៅស្ថិតស្ថេរអស់កល្បជានិច្ចឥតសាបសូន្យ" និង "រាជសម្បត្តិរបស់លោកមិនត្រូវរលាយដែរ" (ខ១៤)។

តើគោលបំណងរបស់ព្រះរាជ្យនេះ គឺជាអ្វី? ទីមួយ កាលដើមដំបូងបង្អស់ ព្រះជាម្ចាស់បានបង្កើតសណ្តាប់ធ្នាប់ខាងឯសីលធម៌ ដែលត្រូវបានដាក់ទៅក្រោមការល្បួងពីសាតាំង និង ផែនដីក៏ធ្លាក់ទៅក្រោមចំណងនៃវិញ្ញាណអាក្រក់មួយនេះ។ ដូច្នេះ វាគឺជាការចាំបាច់ណាស់ ដែលសិរីរុងរឿងរបស់ព្រះជាម្ចាស់ត្រូវបានស្អាងឡើង (ជួយការពារ បង្ហាញថាពិត ឬ ត្រឹមត្រូវ) តាមរយៈជ័យជម្នះលើអំណាចគ្រប់គ្រងរបស់សាតាំង។ នៅពេលដែលឥទ្ធិពលនៃបណ្តាសារត្រូវបានស្រាយចេញ ហើយសាតាំងក៏ត្រូវបានឃុំឃាំង មនុស្សជាតិនឹងអាចមានសេរីភាព ក្នុងការប្រតិបត្តិសេចក្តីស្រឡាញ់ ភាពយុត្តិធម៌ និង ការយកចិត្ត

ទុកដាក់លើព្រះអម្ចាស់ នៅពេលដែលទ្រង់គ្រងរាជ្យនៅក្នុងសមភាព និង សេចក្តីពិត។ ជាលទ្ធផល មនុស្សជាតិនឹងថ្វាយភាពស្មោះត្រង់របស់គេ ទៅកាន់ព្រះអម្ចាស់។ នៅក្នុងព្រះរាជ្យនៃក្តីសន្តោសមេត្តារបស់ទ្រង់ ព្រះអម្ចាស់នៃយើងនឹងបង្ហាញថា សេចក្តីត្រូវការរបស់យើង ត្រូវបានបំពេញជាស្រេច បង្ហាញថា យុត្តិធម៌មានពិត និង បង្ហាញថាសន្តិភាព និង ភាពចុះសម្រុងគ្នាពិតជាអាចកើតឡើងទៅបាននៅលើផែនដីនេះ។

ទីពីរ សម័យកាលនៃព្រះរាជ្យគឺមានភាពចាំបាច់ក្នុងការបំពេញតាមបទទំនាយ។ ព្រះជាម្ចាស់បានសន្យាទៅកាន់ដាវីឌថា កូនចៅជំនាន់ក្រោយរបស់លោក នឹងបានគ្រប់គ្រងជារៀងរហូត (គម្ពីរ២សាំយ៉ូអែល ៧:៨-១៧ គម្ពីរទំនុកតម្កើង ៨៩:៣-៤,១៩-៣៧ គម្ពីរយេរេមា ៣៣:១៤-២៦)។ ដូចដែលយើងបានឃើញហើយថា មានការបកស្រាយមួយនៅក្នុងការគ្រប់គ្រងនេះ គឺថាបទទំនាយនេះនៅ មិនទាន់សម្រេចនៅឡើយ។ ពេលវេលាមួយបានមកដល់ ដែលព្រះយេស៊ូបានប្រសូតចេញពីនាងម៉ារីដែលជាកូនចៅរបស់ដាវីឌ ប៉ុន្តែទ្រង់មិនបានគ្រងរាជ្យនៅលើបល្ល័ង្ករបស់ស្តេចដាវីឌនៅអ៊ីស្រាអែលឡើយ។ ដូច្នេះ បទទំនាយនេះ នៅតែត្រូវរងចាំការសម្រេចនៅថ្ងៃអនាគត ។ (សូមមើលនៅក្នុងគម្ពីរដានីយ៉ែល ២:៣៤-៣៥, ៤៤-៤៥ និងគម្ពីររ៉ូម៨:១៨-២៥ សម្រាប់បទទំនាយដែលទាក់ទងនឹងការនេះ)។

## លក្ខណសម្បត្តិនៃព្រះរាជ្យ

ឯកសារយោងជាច្រើននៅក្នុងបទគម្ពីរ បានជួយឲ្យយើងបានយល់ដឹងបន្ថែមទៀត អំពីការគ្រប់គ្រង និង ស្ថានភាពខាងវិញ្ញាណ ដែលនឹងកើតមាន នៅពេលដែលព្រះអង្គដែលគេចាក់ប្រេងអភិសេកឡើងគ្រងរាជ្យ។ ចូរសិក្សាការទាំងនេះ ដោយយកចិត្តទុកដាក់។

១. នឹងមានការឡើងគ្រងរាជ្យដ៏ពិតជាក់ស្តែងមួយនៅលើផែនដី (គម្ពីរសាការី ១៤:៩)។

២. គ្រានោះ នឹងរាប់បញ្ចូលមនុស្សទាំងអស់ដែលនៅមានជីវិតលើផែនដី (គម្ពីរទំនុកតម្កើង ៧៣:៨-១១ គម្ពីរដានីយ៉ែល៧:១៤ គម្ពីរម៉ាថាយ២៥:៣១-៣២)។

៣. ដោយឥទ្ធិពលនៃបណ្តាសារត្រូវបានស្រាយចេញ ទឹកដីនឹងងាយដាំដុះបង្កើតជាអាហារ។ ពេលនោះនឹងគ្មានគ្រោះទុរភិក្ស ឬ ការខ្វះអាហារទៀតទេ (គម្ពីរអេសាយ ៣៥:១ គម្ពីរមីកា ៤:១-៤)។

៤. ក្រឹត្យវិន័យរបស់ព្រះអម្ចាស់នឹងត្រូវ មនុស្សគ្រប់គ្នាគោរពប្រតិបត្តិ។ ស្របពេលដែលការគ្រប់គ្រងនេះពេញដោយក្តីសប្បុរស និង សន្តោសមេត្តា ក៏វានឹងនៅតែមានភាពម៉ឹងម៉ាត់ផងដែរ។ ការវិនិច្ឆ័យ និង ការយុត្តិធម៌ឥតខ្ចោះ នឹងកើតមានឡើង។ អ្នកណាម្នាក់ដែលបដិសេធមិនស្តាប់បង្គាប់តាម នឹងត្រូវដាក់ទោស (គម្ពីរទំនុកតម្កើង២:៩ គម្ពីរអេសាយ១១:៤; ៦៥:២០ គម្ពីរសាការី ១៤:១៦-១៩)។

៥. អ្វីដែលស្តេចនៃនគរលើផែនដីនេះយកព្រះទ័យទុកដាក់ ច្បាស់ជាអស់អ្នកដែលឆ្លងផុតគ្រាមហាវេទនា ទាំងសាសន៍យូដា និងសាសន៍ដទៃ។

៦. សន្តិភាពនឹងក្លាយជាលក្ខណសម្បត្តិដំបូងនៃនគរដែលដឹកនាំដោយបុត្រានៃសន្តិភាពអង្គនេះ។ ដោយគ្មានឥទ្ធិពលអាក្រក់របស់សាតាំង នោះនឹងគ្មានសង្គ្រាមកើតឡើងទៀតទេ (គម្ពីរអេសាយ ១១:៦-៧)។

៧. ពិតណាស់ អ្នកជឿដែលបានប្រោសលោះហើយ នឹងជួយបម្រើការងារនៅក្នុងនគរនេះ។ ពួកសាវ័ក នឹងគ្រប់គ្រងលើអ៊ីស្រាអែល ហើយមើលទៅដាវីឌនឹងត្រូវ ប្រោសឲ្យរស់ឡើងវិញ ហើយនឹងបម្រើការ ជា អនុប្រឹក្សាភិបាល ដែលនៅក្រោមព្រះអម្ចាស់នៃយើង (គម្ពីរ១កូរិនថូស ៦:២-៣ គម្ពីរវិវរណៈ៥: ១០ គម្ពីរម៉ាថាយ ១៩:២៨; ២៥:៣១ គម្ពីរយេរេមា ៣០:៩ គម្ពីរអេសេគាល ៣៧:២៤-២៥)។

៨. ពិភពរបស់សត្វ នឹងបានផ្លាស់ប្តូរយ៉ាងអស្ចារ្យបំផុត។ សត្វសាហាវនឹងបានស្លូត ហើយសត្វស្លូតក៏ នឹងមិនខ្លាចទៀតដែរ។ ពួកវានឹងរស់នៅជាមួយគ្នាដោយសន្តិភាព (គម្ពីរអេសាយ ១១:៦-៩)។

៩. មនុស្សនឹងប៉ង់ប្រាថ្នាចង់បានព្រះជាម្ចាស់ និង រឿងរ៉ាវខាងឯវិញ្ញាណ។ ពួកគេនឹងសិក្សាព្រះបន្ទូល របស់ព្រះជាម្ចាស់ ដើម្បីឲ្យព្រះតម្រិះរបស់ទ្រង់បានស្តែងឡើងនៅគ្រប់ទីកន្លែង (គម្ពីរអេសាយ ២:៣; ១១:៩ គម្ពីរសាការី ៨:២០-២៣)។

## *លំហាត់អនុវត្តន៍*

---

១៤ តើចម្លើយមួយណានៅខាងក្រោមនេះ ជាគោលបំណងនៃព្រះរាជ្យមួយពាន់ឆ្នាំ?

ក) ដើម្បីផ្តល់ឲ្យសាតាំង ឬ មនុស្សអាក្រក់ដែលបានស្លាប់ទៅហើយ នូវឱកាសជាលើកចុង ក្រោយសម្រាប់ធ្វើការលន់តួ និង បែរត្រឡប់មករកព្រះជាម្ចាស់វិញ។

ខ) ដើម្បីបំពេញតាមបទទំនាយដែលទាក់ទងនឹងកូនចៅជំនាន់ក្រោយរបស់ស្តេចដាវីឌ។

គ) ដើម្បីការពារសិរីរុងរឿងរបស់ព្រះជាម្ចាស់ និង សម្រេចឲ្យបានថាមាគ៌ារបស់ទ្រង់គឺជាមាគ៌ាដ៏ ពិត និង ត្រឹមត្រូវតែមួយគត់។

១៥ ចូរលើកឡើងពីស្ថានភាពនៃលក្ខណសម្បត្តិនៃព្រះរាជ្យមួយពាន់ឆ្នាំនៅខាងក្រោមនេះ ដោយ សរសេរដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

ក) ពិភពរបស់សត្វ

ខ) ក្រឹត្យវិន័យរបស់ព្រះអម្ចាស់

គ) ទីកន្លែងសម្រាប់ព្រះរាជ្យ

ឃ) អ្នកជឿបានប្រោសលោះ ដែលត្រឡប់មកជាមួយព្រះគ្រិស្ត

ង) ស្តេចដាវីឌ

ច) សាសន៍យូដា និង សាសន៍ដទៃ ដែលបានឆ្លងផុតគ្រាមហាវេទនា

ឆ) ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និង រឿងរ៉ាវខាងឯវិញ្ញាណ

ជ) ការបង្កើតអាហារ

# ខ. ការវិនិច្ឆ័យសាតាំង និង មនុស្សអាក្រក់ដែលបានស្លាប់

**វត្ថុបំណងទី៦.** *បកស្រាយមូលហេតុដែលសាតាំង នឹងត្រូវបានដោះលែងមួយរយៈពេលខ្លី បន្ទាប់ពីរយៈពេលមួយសហស្សវត្សរ៍ និង បកស្រាយអំពីគោលបំណងនៃបល្ល័ង្កមួយធំពណ៌ស។*

## ការបោកបញ្ឆោតចុងក្រោយរបស់សាតាំង

នៅចុងបញ្ចប់រយៈពេលមួយសហស្សវត្សរ៍ សាតាំងនឹងត្រូវបានដោះលែងពីការឃុំឃាំង (គម្ពីរវិវរណៈ ២០:៧-១០) ។ សាតាំងនឹង ចេញទៅពាសពេញផែនដីទាំងមូលដើម្បីបញ្ឆោតចិត្តមនុស្សម្តងទៀត ដោយជំរុញឲ្យមានការប្រឆាំងបះបោរទាស់នឹងព្រះអម្ចាស់។ យើងត្រូវបានប្រាប់ឲ្យដឹងថា នឹងមានមនុស្សជាច្រើនចូលរួមជាមួយជួរទ័ពរបស់សាតាំង ហើយវាយប្រឆាំងទាស់នឹងមនុស្សរបស់ព្រះជាម្ចាស់នៅក្នុងរាជធានីរបស់ពួកគេ។

អ្នកប្រហែលជាអាចនឹងសួរថា "តើអាចទៅរួចដែរឬ ដែលមនុស្សរស់នៅក្រោមការគ្រប់គ្រងរបស់ព្រះយេស៊ូជាក្សត្រាហើយ នៅតែអាចក្បត់នឹងទ្រង់ ហើយថែមទាំងជឿថាខ្លួនគេអាចយកឈ្នះនៅក្នុងការទាស់ប្រឆាំងនឹងទ្រង់បានថែមទៀតនោះ?" អ្នកត្រូវចាំថា នៅក្នុងអំឡុងពេលមួយសហស្សវត្សរ៍ សាតាំងត្រូវបានឃុំឃាំង។ មនុស្សទាំងអស់នឹងត្រូវបានតម្រូវឲ្យស្តាប់ប្រតិបត្តិតាមក្រឹត្យវិន័យរបស់នគរព្រះ។ទោះបីក្នុងរយៈពេលមនុស្សស្តាប់បង្គាប់ព្រះអម្ចាស់នៃយើង ក៏នឹងមានមនុស្សជាច្រើនមិនជ្រើសរើសយកព្រះគុណនៃការសង្គ្រោះរបស់ទ្រង់ឡើយ។ ព្រះជាម្ចាស់មិនបង្ខំពួកគេឲ្យទទួលព្រះសង្គ្រោះនោះទេ។ ដូច្នេះគ្រាចុងក្រោយនៃព្រះរាជ្យនេះ មានមនុស្សជាច្រើននឹងបង្ហាញយ៉ាងច្បាស់ ថាមិនបានជឿទៅលើព្រះគ្រិស្តសម្រាប់ការសង្គ្រោះរបស់ពួកគេឡើយ។ បន្ទាប់មកនៅពេលដែលសាតាំងលេចមកជាមួយនឹងការបោកបញ្ឆោតថែមទៀត ដែលជាការកុហកដ៏ធំនោះ ពួកគេនឹងមានឱកាសក្នុងការបះបោរមិនខាន។ ពួកគេនឹងមានសិទ្ធិក្នុងការប្រកាន់សិទ្ធិរបស់ពួកគេ ដើម្បីធ្វើការជ្រើសរើស។

ការបះបោរនេះ នឹងកើតមានឡើងជុំវិញពិភពលោក ហើយនឹងកាន់តែធំទៅៗ រហូតដល់ពេលដែលសាតាំង ដឹកនាំកងទ័ពទៅច្បាំងនឹងជុំររបស់ប្រជារាស្ត្រនៃព្រះជាម្ចាស់។ ទោះជាយ៉ាងណា ព្រះជាម្ចាស់នឹងធ្វើការដាក់ទោសដោយភ្លើងទៅលើពួកអ្នកបះបោរ ហើយពួកគេនឹងត្រូវឆាបឆេះ។ សាតាំងដែលជាអ្នកដឹកនាំពួកគេ នឹងត្រូវឃុំឃាំងជារៀងរហូត ហើយត្រូវដាក់នៅក្នុងបឹងភ្លើង ជាមួយនឹងសត្វតិរច្ឆាននិងព្យាការីក្លែងក្លាយ ជាកន្លែងដែលពួកគេរងទុក្ខវេទនាដោយសារតែវិញ្ញាណបះបោររបស់ពួកគេ។

# ការវិនិច្ឆ័យនៃបល្ល័ង្កពណ៌សធំមួយ

ក្រោយពីមានការបះបោររបស់សាតាំងនេះហើយ ពេលវេលានៃការវិនិច្ឆ័យទោសក៏នឹងមកដល់។ ពេលនោះនឹងជាពេលដ៏អស្ចារ្យមួយ ដែលអ្វីៗសព្វសារពើកំពើកឡើង ដោយសារតែព្រះចេស្តានៃព្រះវត្តមានរបស់ព្រះជាម្ចាស់។ ចំពោះអស់អ្នកដែលបានស្លាប់ទៅ ទាំងមិនបានទទួលស្គាល់សេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ គេនឹងត្រូវបានប្រោសឲ្យរស់ឡើងវិញ ដើម្បីឈរនៅចំពោះ បល្ល័ង្កពណ៌សដ៏ធំអស្ចារ្យ (គម្ពីរវិវរណៈ ២០:១១-១៥)។ អស់អ្នកដែលបានស្លាប់ទៅនៅក្នុងព្រះគ្រិស្ត គេនឹងត្រូវបានត្រាស់ហៅម្ដងទៀត ដោយត្រូវបានប្រោសឲ្យរស់នៅពេលដែលក្រុមជំនុំត្រូវបានឆក់យកឡើងទៅ (គម្ពីរ១ថេស្សាឡូនិក ៤:១៣-១៧)។

អស់ដែលឈរនៅចំពោះ បល្ល័ង្កសដ៏ធំអស្ចារ្យ នឹងត្រូវបានវិនិច្ឆ័យ ដោយផ្អែកលើកិច្ចការដែលគេធ្វើ និង ថាតើឈ្មោះរបស់គេមាននៅក្នុងសៀវភៅនៃជីវិតដែរឬអត់។ នៅពេលដែលការវិនិច្ឆ័យចាប់ផ្ដើម នឹងមានការពិនិត្យឡើងវិញនូវកិច្ចការរបស់មនុស្សម្នាក់ៗ។  បន្ទាប់មកនឹងមានការពិនិត្យពិច័យ ដើម្បីដឹងថាតើឈ្មោះរបស់គាត់គឺមាននៅក្នុងសៀវភៅនៃជីវិតឬទេ។ ដោយសារតែមនុស្សទាំងនេះបានស្លាប់ទៅទាំងដែលមិនបានទទួលសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ ឈ្មោះរបស់ពួកគេក៏នឹងមិនឃើញមាននៅក្នុងសៀវភៅនៃជីវិតដែរ។ បន្ទាប់ពីនោះ បើយោងទៅតាមយុត្តិធម៌ដ៏ល្អឥតខ្ចោះ អ្នកមិនជឿម្នាក់ៗ នឹងត្រូវទទួលការដាក់ទោសឲ្យជាប់ឃុំឃាំងអស់កល្បជានិច្ច នៅក្នុងបឹងភ្លើង។ ការបោះបង់នេះ គឺមិនត្រឹមតែទៅក្នុងភ្លើងដែលឆេះអស់កល្បជានិច្ចនោះទេ ប៉ុន្តែក៏ទៅក្នុងកន្លែងងងឹតអន្ធកា និង គួរឲ្យរន្ធត់ផងដែរ។ ព្រះយេស៊ូបានមានព្រះបន្ទូលអំពីការដ៏គួរឲ្យរន្ធត់នេះ ហើយទ្រង់ថែមទាំងបានបង្ហាញថា វានឹងធ្វើឲ្យមនុស្សសម្រកទឹកភ្នែក និង សង្កៀតធ្មេញរបស់ពួកគេ (គម្ពីរម៉ាថាយ៨:១២; ១៣:៤២; ២២:១៣; ២៤:៥១; ២៥:៣០)។ ក្រោយមកទៀត តាមរបៀបនេះ ព្រះជាម្ចាស់បញ្ចប់ការអាក្រក់ ហើយលុបវាចោលជារៀងរហូត។

## *លំហាត់អនុវត្តន៍*

---

១៦ ចូរបំពេញប្រយោគខាងក្រោម៖

ក) មូលហេតុដែលសាតាំងនឹងត្រូវបានដោះលែងមួយរយៈពេលខ្លី បន្ទាប់ពីរយៈពេលមួយសហស្សវត្សរ៍ នោះគឺដើម្បី..........................................................................................

ខ) គោលបំណងនៃការវិនិច្ឆ័យពីបល្ល័ង្កពណ៌សដ៏ធំអស្ចារ្យ គឺដើម្បី.........................................

# ច. ការបង្កើតថ្មី

**វត្ថុបំណងទី៧.** *ប្រាប់ពីមូលដ្ឋានគ្រឹះដែលអ្នករំពឹងទុកថាជាទិដ្ឋភាពមួយនៃការបង្កើតថ្មីដែលព្រះជាម្ចាស់បានបង្កើតឡើង។*

លោកសាវ័កពេត្រុសបានលើកឡើងនៅក្នុងសំណេររបស់លោកថា អ្វីៗនឹងត្រូវបានឆេះឡើង។ វាហាក់បីដូចជាផែនដីនឹងត្រូវបានឆ្លងកាត់ការកែតម្រូវ (ផ្លាស់ប្តូរ ឬ ធ្វើឲ្យថ្មីឡើង) ដោយសារភ្លើង (គម្ពីរអេសាយ ៦៥:១៧ គម្ពីរ២ពេត្រុស ៣:៧)។ ទោះជាយ៉ាងណា លោកសាវ័កបាននិយាយថា ក្រោយពីភាពចលាចលខ្លាំងនេះហើយ យើងនឹងទន្ទឹងរងចាំ " ផ្ទៃមេឃថ្មី និងផែនដីថ្មី ដែលមានសុទ្ធតែសេចក្តីសុចរិតវិញ។ (គម្ពីរ២ពេត្រុស ៣:១០-១៣ គម្ពីរពគប)។ ដូច្នេះហើយ ព្រះជាម្ចាស់នឹង នាំប្រជាជនស្មោះត្រង់របស់ទ្រង់ទៅក្នុងស្ថានព្រះហស្តដ៏មានសិរីរុងរឿង និង ស្ថិតស្ថេរអស់កល្បជានិច្ច។

នៅក្នុងអំឡុងពេលមួយសហស្សវត្សរ៍ ដែលជាយុគសម័យដ៏ល្អឯក អ្នកជឿនឹងឈានឆ្ពោះទៅផុតយុគសម័យនេះ ចូលទៅក្នុងយុគសម័យថ្មីមួយដែលព្រះជាម្ចាស់គឺជាអ្វីៗគ្រប់ទាំងអស់។ នៅក្នុងការបង្កើតថ្មីនេះ ព្រះជាម្ចាស់នឹងសង់ដំណាក់របស់ទ្រង់នៅលើផែនដី។ ទីក្រុងដែលទ្រង់បានរៀបចំគឺល្អហួសការថ្លែង (គម្ពីរ១កូរិនថូស ២:៩-១០) ទីក្រុងនោះ ល្អស្អាតលើសអ្វីៗគ្រប់យ៉ាងដែលយើងធ្លាប់ឃើញពីមុនមក (គម្ពីរវិវរណៈ ជំពូក២១-២២)។

ជីវិតអស់កល្បជានិច្ចដែលមនុស្សបានយល់ឃើញ គឺមិនមែនជាអ្វីដែលគ្មានការផ្លាស់ប្តូរ ឬប្រែប្រួលនោះទេ ហើយព្រះជាម្ចាស់ផ្ទាល់ ទ្រង់ក៏មិនឈប់សម្រាក នៅពេលដែលផែនការរបស់ទ្រង់បានសម្រេចនោះដែរ។ ទ្រង់គឺជាព្រះជាម្ចាស់ដែលមានព្រះជន្មរស់ ហើយយើងត្រូវតែបានដូចទ្រង់! ទ្រង់បានបង្កើតសាកលលោកដ៏ធំល្វឹងល្វើយ ដែលហាក់បីដូចជាបន្តការផ្លាស់ប្តូររហូតតទៅ។ ឥឡូវនេះយើងឃើញពីការនេះព្រាលៗប៉ុណ្ណោះ តែនៅក្នុងយុគសម័យក្រោយៗទៀត យើងនឹងមានពេលរហូតតទៅ ក្នុងការយល់ដឹងពីការអស្ចារ្យនៃ ស្ថានព្រះហស្តជាបន្តបន្ទាប់របស់ទ្រង់ (គម្ពីរ១កូរិនថូស ១៣:១២)។ យើងនឹងអាចរួមច្រៀងជាមួយមនុស្សជំនាន់មុន ជុំវិញរាជបល្ល័ង្កនៅពេលដែលពួកគេច្រៀងថ្វាយការសរសើរទៅកាន់ព្រះជាម្ចាស់នៃយើង៖ "បពិត្រព្រះអម្ចាស់ជាព្រះនៃយើងខ្ញុំ ព្រះអង្គសមនឹងទទួលសិរីរុងរឿង ព្រះកិត្តិនាម និងឫទ្ធានុភាព ដ្បិតព្រះអង្គបានបង្កើតរបស់សព្វសារពើមក អ្វីៗទាំងអស់សុទ្ធតែកើតមាន ហើយនៅស្ថិតស្ថេរដោយសារព្រះហឫទ័យរបស់ព្រះអង្គ"។ (គម្ពីរវិវរណៈ ៤:១១)។

យើងត្រូវត្រឡប់ទៅមើលប្រវត្តិសាស្ត្រដែលបានលាតត្រដាង តាំងពេលដែលទេវតាបាននិយាយថា ព្រះយេស៊ូនឹងយាងមកម្តងទៀត (គម្ពីរកិច្ចការ ១:១១)។ មានរឿងជាច្រើនបានកើតឡើង! មានបទទំនាយជាច្រើន បានកើតឡើងមានពិត។ មានព្រឹត្តិការណ៍ជាច្រើនបានរុញច្រានយើង ឲ្យបានមកដល់ពេលដែលយើងកំពុងតែឈរនេះ៖ "*គឺយើងឈរនៅលើដំណាក់កាលចុងក្រោយបំផុត នៃផែនការរបស់ព្រះជាម្ចាស់*។ យើងមានអំណរ ដ្បិតយើងខិតជិតដល់ថ្ងៃនៃការប្រោសលោះចុងក្រោយហើយ។ យើងត្រូវចងចាំជានិច្ចថា ការបង្កើតថ្មីកំពុងតែរងចាំពួកយើង ជាមួយនឹងព្រះយេស៊ូជាស្តេចរបស់យើង! ព្រះយេស៊ូបានមានព្រះបន្ទូលថា " ចូរស្តាប់ យើងនឹងមកដល់ក្នុងពេលឆាប់ៗ អ្នកណាប្រតិបត្តិតាមសេចក្តីដែលមានថ្លែងទុកក្នុង

សៀវភៅនេះ អ្នកនោះមានសុភមង្គលហើយ!" (គម្ពីរវិវរណៈ ២២:៧) ។ បន្ទាប់មកយើងរាល់គ្នា ដែលជាផលនៃការប្រោសលោះរបស់ព្រះអម្ចាស់ ទូលតបថា៖ "អាម៉ែន ។ សូមព្រះអម្ចាស់យេស៊ូយាងមក!"

## *លំហាត់អនុវត្តន៍*

១៧ ចូរពិនិត្យមើលខ្លួនឯង នៅពេលដែលយើងបញ្ចប់មេរៀននេះ ហើយសរសេរនៅក្នុងសៀវភៅកត់ត្រារបស់អ្នកនូវគោលជំហរដែលអ្នករំពឹងទុកថាបានក្លាយជាទិដ្ឋភាពមួយនៃការបង្កើតថ្មីដែលព្រះជាម្ចាស់នឹងបង្កើតឡើង (សូមមើលនៅក្នុងគម្ពីរវិវរណៈ ២២:១២-១៧)។

---

នៅពេលដែលយើងបញ្ចប់ការសិក្សានេះ យើងត្រូវតែចងចាំនៅក្នុងចិត្តថា ការសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពិតជាមានតម្លៃខាងឯក្រមសីលធម៌មួយមែន ជាពិសេសនៅក្នុងព្រះបន្ទូលអំពីបទទំនាយៈ

> កូនចៅជាទីស្រឡាញ់អើយ! ពេលនេះ យើងទាំងអស់គ្នាជាបុត្ររបស់ព្រះជាម្ចាស់ ហើយដែលយើងនឹងទៅជាយ៉ាងណាៗនោះព្រះអង្គពុំទាន់សំដែងអោយយើងដឹងនៅឡើយទេ។ ប៉ុន្តែ នៅពេលព្រះគ្រិស្តយាងមកដល់ យើងនឹងបានដូចព្រះអង្គដែរ ដ្បិតព្រះអង្គមានភាពយ៉ាងណា យើងនឹងឃើញព្រះអង្គយ៉ាងនោះ។ អ្នកណាមានសេចក្ដីសង្ឃឹមលើព្រះអង្គបែបនេះ អ្នកនោះបានជំរះខ្លួនអោយបរិសុទ្ធ* ដូចព្រះអង្គបរិសុទ្ធដែរ។ (គម្ពីរ១យ៉ូហាន៣:២-៣)

# ការប្រឡងផ្ទាល់ខ្លួន

ត្រូវ- ខុស។ ចូរសរសេរអក្សរ ត នៅក្នុងចន្លោះបន្ទាត់ប្រសិនបើប្រយោគនោះជាចម្លើយត្រឹមត្រូវ។ សរសេរអក្សរ ខ ប្រសិនបើប្រយោគខុស។

.........១ ព្រឹត្តិការណ៍ដែលនឹងកើតឡើងនៅលើផែនដី បន្ទាប់ពីមានការឆក់យកឡើងទៅ គេហៅថា៖ "ព្រះពរនៃក្តីសង្ឃឹម" ។

.........២ ការឆក់យកឡើងទៅ និង ការបើកសម្តែងរបស់ព្រះគ្រិស្ត គឺជាព្រឹត្តិការណ៍ពីរដាច់ដោយឡែកពីគ្នា ។ នៅក្នុងការយាងមកលើកទីមួយ ទ្រង់យាងមក*ដើម្បី*មនុស្ស របស់ទ្រង់ ហើយនៅក្នុងការយាងមកជាលើកទីពីរ ពួកមនុស្សទាំងនោះនឹងយាងមក*ជាមួយទ្រង់* ដែរ

.........៣ ថ្ងៃ និង ម៉ោងដែលព្រះយេស៊ូនឹងយាងមក អាចធ្វើការកំណត់បានដោយសិក្សា ការរាប់រៀបអំពីបញ្ជីនីមួយៗមានវគ្គ "៧" នៅក្នុងគម្ពីរដានីយ៉ែលជំពូក ៩។

.........៤ អ្នកជឿទាំងមនុស្សស្លាប់ និង មនុស្សរស់ សុទ្ធតែត្រូវបានរាប់បញ្ចូលទៅក្នុងការឆក់យកឡើងទៅ។

..........៥ ព្រះគម្ពីរបានបង្ហាញថា នឹងមានកម្រិតនៃរង្វាន់សម្រាប់អ្នកជឿគ្រប់គ្នា។

..........៦ បទទំនាយភាគច្រើននៅក្នុងគម្ពីរដានីយ៉ែលជំពូក៩ គឺបានសម្រេចរួចទៅហើយ។

.........៧ *ព្រះអង្គដែលគេចាក់ប្រេងអភិសេកដែលត្រូវគេធ្វើគុត* គឺនិយាយសំដៅទៅអ្នកប្រឆាំងនឹងព្រះគ្រិស្ត។

..........៨ គ្រាមហាវេទនា នឹងមានរយៈពេលប្រាំពីរឆ្នាំ ហើយបានពាក់កណ្តាលរយៈពេលប្រាំឆ្នាំនេះ អ្នកប្រឆាំងនឹងព្រះគ្រិស្តនឹងក្បត់សន្យាដែលគេធ្វើជាមួយពួកយូដា។

...........៩ អ៊ីស្រាអែលត្រូវបានខ្ចាត់ខ្ចាយចេញពីទឹកដីសន្យាដោយព្រោះតែការមិនស្តាប់បង្គាប់។

..........១០ ការកើតជាថ្មីរបស់សាសន៍អ៊ីស្រាអែល នៅខែឧសភាក្នុងឆ្នាំ១៩៤៨ គឺជាការបំពេញតាមបទទំនាយមួយ។

..........១១ អ្នកប្រឆាំងនឹងព្រះគ្រិស្តនឹងនាំយកសន្តិភាពយ៉ាងមានស្ថេរភាពមកឲ្យពិភពលោក ក្នុងរយៈពេល១០០០ឆ្នាំ។

..........១២ មានតែប្រជាជនយូដាតែប៉ុណ្ណោះដែលនឹង តម្រូវឲ្យមានសញ្ញាសំគាល់របស់អ្នកប្រឆាំងនឹងព្រះគ្រិស្ត ដើម្បីឲ្យពួកគេអាចធ្វើមុខជំនួញបាន។

..........១៣ អើម៉ាគេដូន នឹងក្លាយទៅសមរភូមិដ៏គួរឲ្យខ្លាចមួយ រវាងសាសន៍យូដា និង សត្រូវរបស់គេដែលក្នុងសមរភូមិនោះ ក្រុងយេរូសាឡឹមនឹង ប្រជាជនក្នុងនោះនឹងត្រូវបំផ្លាញ។

..........១៤ ការបើកសម្តែងរបស់ព្រះយេស៊ូគ្រិស្តនឹងកើតឡើង នៅពេលដែលមានការបៀតបៀនពួកយូដា និង ការមិនគោរពកោតខ្លាចព្រះជាម្ចាស់របស់មនុស្សលោក ឈានដល់កម្រិតធ្ងន់ធ្ងរមួយ។

..........១៥ នៅក្នុងការបើកសម្តែងរបស់ព្រះយេស៊ូគ្រិស្ត មនុស្សទទឹងច្បាប់ និង ទ័ពរបស់គេ នឹង ចាញ់សង្គ្រាម ហើយព្រះយេស៊ូនឹងត្រូវបានបើកសម្តែងជាស្តេចលើអស់ទាំងស្តេច និង ជាព្រះអម្ចាស់លើអស់ទាំងអម្ចាស់។

# ចម្លើយសម្រាប់លំហាត់អនុវត្តន៍

៩ ក) ការនិរទេសរបស់ពួកយូដាអស់រយៈពេល៧០ឆ្នាំ គឺដោយសារតែការមិនស្តាប់បង្គាប់។

ខ) ការជួសជុល និង ការសាងសង់ក្រុងយេរូសាឡឹមឡើងវិញ គឺកើតឡើងក្រោយការជាប់ជាទាសកររយៈពេល៧០ឆ្នាំ។

គ) ការយាងមករបស់លោកដែលគេចាក់ប្រេងអភិសេក។

ង) ការសម្លាប់លោកដែលគេចាក់ប្រេងអភិសេក។

ច) មនុស្សរបស់ស្តេចដែលកំពុងយាងមក កំទេចទីក្រុងដ៏វិសុទ្ធ និង ព្រះវិហារ។

ឆ) ទីបញ្ចប់ជាអធិបតេយ្យភាព របស់សាសន៍យូដា។

ជ) បទទំនាយនៅក្នុងគម្ពីរអេម៉ុស ៩ ដែលប្រាប់ថាប្រទេសអ៊ីស្រាអែល នឹងត្រូវបានស្រោចស្រង់ឡើងវិញម្តងទៀត ហើយប្រជារាស្ត្រគេនឹងត្រឡប់មកធ្វើចំការ និង ដាំទំពាំងបាយជូរម្តងទៀត។

១ ខ) ការឆក់យកអ្នកជឿឡើងទៅ នៅពេលដែលព្រះគ្រិស្តយាងមក សម្រាប់ពួកគេ។

១០ ក), ខ), ឃ), ឆ), ជ) និង ញ) ជាចម្លើយត្រឹមត្រូវ។

២ ការយាងត្រឡប់មកវិញរបស់ទ្រង់នឹង មកដល់មិនយូរប៉ុន្មានក្រោយពេលដំណឹងល្អ ត្រូវបានចែកចាយទៅកាន់ពិភពលោកទាំងមូល។ គ្មាននរណាម្នាក់ដឹងថាថ្ងៃណា ឬ ម៉ោងណានោះទេ។

១១ ខ) នាំមកនូវការវិនិច្ឆ័យចុងក្រោយ ដល់មនុស្សមានបាបទាំងឡាយណាដែលបដិសេធមិនទទួលយកទ្រង់។

៣ ក) មនុស្សស្លាប់ , មនុស្សរស់

ខ) ព្រះបន្ទូលរបស់ព្រះអម្ចាស់ផ្ទាល់

គ) សេចក្តីសង្ឃឹម

១២ ការមិនគោរពកោតខ្លាចព្រះជាម្ចាស់ ឬ ភាពពេញដោយបាប និង ភាពអាត្មានិយមជាច្រើនរបស់មនុស្សជាតិ ព្រមទាំងការបៀតបៀនយ៉ាងខ្លាំងទៅលើសាសន៍អ៊ីស្រាអែល។

៤ មនុស្សទាំងពីរប្រភេទនេះ នឹងទទួលបានរូបកាយថ្មីប្រកបដោយសិរីរុងរឿង ដែលមិនចេះស្លាប់ និង មិនចេះរលាយសាបសូន្យ។

១៣ សាតាំង និង កងទ័ពរបស់វា នឹងត្រូវដកចេញពីការកាន់អំណាច និង ត្រូវបោះចូលទៅក្នុងបឹងភ្លើង។ ព្រះយេស៊ូនឹងឡើងគ្រង់ដំណែងពេញសិទ្ធិរបស់ទ្រង់ ក្នុងនាមជាស្តេចលើអស់ទាំងស្តេច និង ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់។

៥ គ) ទទួលបានរង្វាន់មួយដែលផ្អែកលើបំណងចិត្ត ឬ គុណភាពនៃការបម្រើរបស់គេ។

១៤ ខ) ដើម្បីបំពេញតាមបទទំនាយដែលទាក់ទងនឹងកូនចៅជំនាន់ក្រោយរបស់ស្តេចដាវីឌ។

គ) ដើម្បីការពារសិរីរុងរឿងរបស់ព្រះជាម្ចាស់ និង សម្រេចឲ្យបានថាមាគ៌ារបស់ទ្រង់គឺជាមាគ៌ាដ៏ពិត និង ត្រឹមត្រូវតែមួយគត់។

៦ ក) ជារូបកាយមិនចេះស្លាប់ មិនចេះរលាយសាបសូន្យ ដែលត្រូវជំនួសរូបកាយខាងឯសាច់ឈាម នៅក្នុងពេលនៃការឆក់យកឡើងទៅ។

ខ) នៅពេលដែលព្រះយេស៊ូយាងត្រឡប់មកជាមួយមនុស្សរបស់ទ្រង់ ដើម្បីបង្កើតព្រះរាជ្យរបស់ទ្រង់។

គ) នៅពេលដែលព្រះយេស៊ូយាងមកដើម្បីមនុស្សរបស់ទ្រង់៖ អ្នកស្លាប់នៅក្នុងព្រះគ្រិស្តនឹងត្រូវបានប្រោសឲ្យរស់ឡើងវិញជាមុនសិន បន្ទាប់មកអ្នកជឿដែលកំពុងមានជីវិតរស់ នឹងត្រូវបានលើកឡើងទៅគាល់ទ្រង់នៅលើអាកាស។

ឃ) ការយាងមកជាលើកទីពីររបស់ព្រះគ្រិស្ត (ការឆក់អ្នកជឿឡើងទៅ)។

ង) "ទីកាត់ក្តី" ដែលព្រះយេស៊ូនឹងវិនិច្ឆ័យកិច្ចការរបស់អ្នកជឿ ហើយនឹងមានការប្រទានរង្វាន់ដោយផ្អែកលើគុណភាពនៃជីវិត និង ការបម្រើក្នុងនាមជាគ្រិស្តបរិស័ទរបស់ពួកគេ។

១៥ ក) សត្វទាំងអស់នឹងរស់នៅជាមួយគ្នា ប្រកបដោយសន្តិភាព។

ខ) នឹងត្រូវបានគេស្តាប់បង្គាប់ ហើយនឹងមានការវិនិច្ឆ័យ និង យុត្តិធម៌ដ៏ល្អឥតខ្ចោះ។

គ) ផែនដី

ឃ) នឹងគ្រងរាជ្យជាមួយព្រះគ្រិស្ត

ង) នឹងបម្រើការជាអនុប្រឹក្សាភិបាល របស់ព្រះគ្រិស្ត

ច) នឹងស្ថិតនៅក្រោមអំណាច របស់ស្តេចនៃស្ថានបរមសុខ

ឆ) នឹងត្រូវទទួលបានការចាប់អារម្មណ៍ និង ធ្វើការសិក្សា

ជ) នឹងបានពេញបរិបូរណ៍

៧ ក) រយៈពេលដែលពួកយូដាមិនបានប្រតិបត្តិតាម ឆ្នាំសប្ប័ទរបស់ពួកគេ។

១៦ ក) ដើម្បីផ្តល់ឲ្យមនុស្សដែលរស់នៅលើផែនដី នូវឱកាសក្នុងការ សម្រេចចិត្តជ្រើសរើសយកព្រះជាម្ចាស់ ឬ ទាស់ប្រឆាំងនឹងទ្រង់។

ខ) ធ្វើឲ្យមានការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ ទៅលើមនុស្សអាក្រក់ ដោយផ្អែកលើ ថាតើឈ្មោះរបស់ពួកគេ មានសរសេរចុះនៅក្នុងសៀវភៅនៃជីវិតឬអត់។

៨ ការបំផ្លាញព្រះវិហារ នៅក្នុងឆ្នាំ៧០ គ.ស។

១៧ ចម្លើយរបស់អ្នក។ ការបង្កើតថ្មីគឺសម្រាប់អស់អ្នកដែលទទួលស្គាល់ព្រះយេស៊ូជាព្រះអម្ចាស់នៃជីវិតរបស់ពួកគេ ដែលមានឈ្មោះកត់ទុកក្នុងសៀវភៅនៃជីវិត នឹងទន្ទឹងរង់ចាំការយាងត្រឡប់មកវិញរបស់ទ្រង់។

**សូមចូលរួមអបអរសាទរ**

ឥឡូវនេះអ្នកបានបញ្ចប់មេរៀននៅក្នុងជំពូកចប់សព្វគ្រប់ហើយ។ យើងសង្ឃឹមថាវាជាជំនួយ ដ៏ល្អសម្រាប់អ្នក។ ចូររំឭកមេរៀនទាំងអស់នៅក្នុងជំពូកទី៣ ហើយធ្វើ*ការវាយប្រឡងជំពូកទីបីនេះ*។